# រំលឹក ហ៊ុន សែន

ជាការពិត និង ឥតប្រកែកបានថា ក្នុងរយះពេល 33 ឆ្នាំក្រោយ របបកម្ពុជាប្រជាធិបតេយ្យប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានដួលរលំទៅហើយ តែមិនរលាយបាត់រូប រហូតមកដល់សព្វថ្ងៃនេះព្រោះតែហេតុអ្វី ? គឺព្រោះតែមានជនកម្មុយនិស្តជួយជ្រុំជ្រែង និង លើកតំកើងមកវិញហ្នឹងឯង សួរថាជនទាំងនោះមាននរណាខ្លះ ?

**ជនទាំងនោះគឺមាន ៖**

1- ស្តេចកម្មុយនិស្ត នរោត្តម សីហនុ ដែលមានរដ្ឋាភិបាលចិនកម្មុយនិស្ត ឈរនៅពីក្រោយ ។

2- ជនកម្មុយនិស្ត ហ៊ុន សែន - ជា ស៊ីម - ហេង សំរិន និង គណបក្សប្រជាជនកម្ពុជា ដែលមានរដ្ឋាភិបាលយួនកម្មុយនិស្ត ក្រុងហាណូយ ឈរនៅពីក្រោយ ។

សូមរំលឹកថា ប្រជាជាតិ និង មាតុភូមិខ្មែរយើងត្រូវបានគេកាប់សម្លាប់ និង បំផ្លិចបំផ្លាញចាប់តាំងពីថ្ងៃទី 17 ខែមេសា ឆ្នាំ 1975 រហូតមកដល់សព្វថ្ងៃនេះ គឺដោយសារតែ គណបក្សកម្មុយនិស្តមួយនេះ វាជាគណបក្ស ដែលបង្កើតឡើងដោយយួនកម្មុយនិស្ត ហូ ជី មិញ កាលពីថ្ងៃទី28 ខែមិថុនា ឆ្នាំ 1951 ។

ដូច្នេះ បើយើងមើលទៅតាមអ្វីដូចដែលបានរៀបរាប់ និង អធិប្បាយ មកខាងលើនេះ សួរថាតើប្រទេសខ្មែរយើងនៅមានសង្ឃឹមទៀតឬ ថានឹងមានលទ្ធិប្រជាធិបតេយ្យសេរីពិតប្រាកដ នាពេលអនាគត?

**ថ្ងៃនេះយើង ខេម រិទ្ធ សូមដាក់ខ្លួនធ្វើជាកញ្ចក់ឆ្លុះមួយផ្ទាំងអោយដល់លោក ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ដើម្បីឆ្លុះមើលនូវ អ្វីដែលខ្លួនបានធ្វើ កំពុងធ្វើ និង កំពុងបន្តធ្វើនាពេលអនាគត ។**

យើងជាខ្មែរ ជាអ្នកតស៊ូម្នាក់ក្នុងរណសិរ្ស(FUNCINPEC)នៅតាមបណ្តោយព្រំដែនខ្មែរ - ថៃ ដែលជាការតស៊ូដោយកម្លាំងប្រដាប់អាវុធ ដើម្បី ប្រឆាំង និង បណ្តេញ សត្រូវយួនកម្មុយនិស្តឈ្លានពានចេញអោយអស់ពីប្រទេសកម្ពុជាយើងនាពេលនោះ ។

លទ្ធផល គឺសត្រូវយួនឈ្លានពានគេបានសម្តែងអោយ ជាតិ និង អន្តរជាតិ បានឃើញនឹងភ្នែកហើយថា ពួកគេបានដកកម្លាំងទ័ពទាំងអស់ ចេញពីប្រទេសកម្ពុជាយើងមែន កាលពី ខែកញ្ញា ឆ្នាំ 1989 ។

ប៉ុន្តែរឿងរ៉ាវទាំងអស់នោះ វាគ្រាន់តែជា ឆាកល្ខោននយោបាយ ដ៏ខ្មៅក្រខ្វក់កុហក់មនុស្សទាំងពិភពលោក ដែលយួនក្រុងហាណូយ និង លោក ហ៊ុន សែន ចាត់ធ្វើឡើងដើម្បីជាការបោកប្រាស ជាការបំភ័ន្តភ្នែក ជាតិ និង អន្តរជាតិ តែប៉ុណ្ណោះ ។

សកម្មភាព បោកប្រាស ទាំងអស់ហ្នឹង នរណាក៏គេដឹងដែរថា កម្លាំងទ័ពយួន ទាំងប៉ុន្មានដែលបានចេញពីប្រទេសកម្ពុជានាពេលនោះ គឺ ត្រូវបានរដ្ឋាភិបាល យួន ក្រុងហាណូយ បញ្ជូនអោយត្រឡប់ ចូលមកក្នុងប្រទេសកម្ពុជាវិញទាំងអស់ តាមរូបភាពជាជនសីវិល ចំណែកគ្រឿងអាវុធយុទ្ធភ័ណ្ឌដែលបាននាំចេញនៅពេលនោះគឺ សុទ្ធតែជាអាវុធចាស់ៗខូចខាតប្រើការលែងកើត ។

**ហេតុអ្វីបានជាពួកគេហ៊ានធ្វើរបៀបនេះ ?**

1-ព្រោះថាយួនក្រុងហាណូយត្រូវការជាចាំបាច់បំផុតនៅកម្លាំងទ័ពយួនទាំងអស់ហ្នឹង ដើម្បី រក្សា និង ការពារ អោយ រដ្ឋាភិបាលអាយ៉ងរបស់គេដែលមាន ហ៊ុន សែន ជាប្រមុខ បានរស់រានមានជីវិតរហូត ដល់ពេលកម្លាំងទ័ពរបស់អង្គការ សហប្រជាជាតិ (UNTAC) ចូលមកដល់កម្ពុជា ។

2- ជាល្បិចកល់មួយដើម្បី រក្សាទុក នៅកម្លាំងទ័ពរបស់យួនទាំងអស់អោយនៅជារៀងរហូតក្នុងប្រទេសកម្ពុជាយើង ក្នុងគោលដៅលេបបំបាត់ពូជសាសន៍ខ្មែរនាពេលខាងមុខ ។

***ក្នុងគោលគំនិតដ៏ស៊ីជម្រៅរបស់រដ្ឋាភិបាលយួន ក្រុងហាណូយ នាពេលនោះបានមើលឃើញ និង បានយល់យ៉ាងច្បាស់ថា ៖***

1- កម្លាំងទ័ពរបស់អ្នកតស៊ូខ្មែរត្រីភាគី ដែលមាន*(នរោត្តម សីហនុ-ស៊ឺន សាន នឹង ប៉ុល ពត)*ជាអ្នកដឹកនាំផ្ទាលនាពេលនោះ ពិតជានិងវាយដណ្តើមយកអំណាច ពីរដ្ឋាភិបាលអាយ៉ងកញ្ជះយួន ហ៊ុន សែន បានដោយងាយស្រួលជាទីបំផុត *បើគ្មានកម្លាំងទ័ពយួននៅការពាររក្សាទេនោះ ។*

*2-ជាឱកាសដ៏មហាសែនល្អ និង កម្ររកបានដែលសត្រូវយួនអាចដណ្តើមយកជាតិ មាតុភូមិកម្ពុជាយើងទាំងមូល មកធ្វើជារបស់គេ ដោយស្របច្បាប់ ដោយមិនចាំបាច់បញ្ជូនកម្លាំងទ័ពអោយចូលមកក្នុងកម្ពុជាជាថ្មី ដើម្បីច្បាំងដណ្តើមយកម្តងហើយម្តងទៀតដូចកាលមុនៗនោះឡើយ ។*

3-ឆ្លៀតក្នុងឪកាសនោះ ដែលរដ្ឋាភិបាលអាយ៉ងកញ្ជះយួន ហ៊ុន សែន កំពុងតែ *ទន់ខ្សោយ និង ចាញ់ប្រៀប* យ៉ាងខ្លាំងទៅលើកម្លាំងអ្នកតស៊ូនាពេលនោះ ក្រុងហាណូយ បានទាញយកឪកាសដ៏ល្អនេះ បញ្ជូន និង បញ្ចូល មកបន្ថែមនៅនិគមន៍ ជនជាតិយួនយ៉ាងច្រើនសន្ធឹកសន្ធាប់អោយចូលមករស់នៅ ដោយស្របច្បាប់ក្នុងប្រទេសកម្ពុជាយើង**ដោយសំអាងទៅលើសន្លឹកឆ្នោតនាពេលខាងមុខ ៗ**

លោក ហ៊ុន សែន និង គណបក្ស *ប្រជាជនបដិវត្តកម្ពុជា* នាពេលនោះ បានមើលឃើញ និង យល់យ៉ាងច្បាស់នូវ *សភាពការណ៍ និង ស្ថានការណ៍ពិត* ថាខ្លួនពិតជា *ខ្សោយ គឺ ខ្សោយ ដូចមនុស្សកើតអេដ៍(AIDS)* អញ្ចឹងមិនអាចជួយខ្លួនឯងបាន និង *មិនអាចប្រកែកបានទៅទៀត នូវបំណង ប្រាថ្នាល្អរបស់យួន កុម្មុយនិស្ត ក្រុងហាណូយ ដែលបានផ្តល់អោយពួកខ្លួននាពេលនោះ ក៏ សុខចិត្ត ព្រមកាយ ទៅតាមក្តីប្រាថ្នានោះតែម្តងទៅ ។*

**ខាងក្រោមនេះយើងសូមធ្វើការក្រើនរំលឹកខ្លីៗនូវប្រវត្តិសាស្ត្រជាតិខ្មែរយើង ៖**

*ជាតិខ្មែរយើងជាប្រជាជាតិដើមមួយនៅក្នុងទ្វិបអាស៊ីអាគ្នេយ៍យើងនេះ មានអាយុរាប់ពាន់ឆ្នាំមកហើយៗយើងមានសមិទ្ធិផលដ៏មហិមាដែលមហាបុព្វបុរសខ្មែរយើងបានកសាងទុកអោយជាកេរ៍ដំណែលមានដូចជា អង្គរវត្ត អង្គរធំ ព្រមទាំងប្រាង្គប្រាសាទជាច្រើនទៀតរាប់មិនអស់ដែលមាននៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃ ។*

*អង្គរវត្ត អង្គរធំ និង ប្រាង្គប្រាសាទទាំងអស់ហ្នឹង បានធ្វើអោយមនុស្សទូទាំងពិភពលោកបានស្គាល់នូវ អ្វីដែលជា អត្តសញ្ញាណរបស់ជាតិខ្មែរពិតប្រាកដ កន្លងមក ប្រជាជាតិខ្មែរយើងមានមោទនភាពជាតិ ខ្លាំងណាស់ហើយត្រូវបានពិភពលោក និង មនុស្សគ្រប់ជាតិសាសន៍ទទួលស្គាល់ថាជាសំណង់ដ៏មហិមា និងមហាអស្ចារ្យ របស់ពិភពលោកយើងនេះ ។*

*ជាតិខ្មែរយើងដែលធ្លាប់តែមាន មោទនភាព ធ្លាប់តែមាន ភាពរុងរឿងឧត្តុងឧត្តម ធ្លាប់តែមាន វឌ្ឍនធម៌ និង អរិយធម៌ខ្ពង់ខ្ពស់ មានកិត្យានុភាពខ្លាំងក្លា ល្បីល្បាញ ខ្ទរខ្ទារ លើទ្វីបអាស៊ីអាគ្នេយ៍ទាំងមូល ។*

*ពីអតីតកាលដែលគួរអោយ មោទនៈ និង បច្ចុប្បន្នកាល ដែលគួរអោយ ឈឺចាប់ខ្លោចផ្សារ មហាទុក្ខវេទនា អស់រយៈពេលជាច្រើនទស្សវត្សន៍មកហើយ ដែលប្រជាជាតិ និង មាតុភូមិខ្មែរយើង បានជួបប្រទះតែសង្គ្រាមបង្ហូរឈាមរវាង ខ្មែរនិងខ្មែរ ដែលបង្ករឡើងដោយ មេដឹកនាំដែលជាខ្ញុំកញ្ជះបរទេស មានចិន មានយួន បារាំង អាមេរិកាំង សៀម ។ល។និង។ល។។*

*ពួកមេដឹកនាំខ្មែរ ទាំងអតីតកាល ទាំង បច្ចុប្បន្នកាល ទាំងស្តេច ទាំងរាស្ត្រ គ្មានមួយណាគិត ឬ បំពេញប្រយោជន៍ដើម្បី ជាតិ និង ប្រជាជនរបស់ខ្លួនឡើយ ពួកគេម្នាក់ៗគិតតែពីរឿងអំណាច និងផលប្រយោជន៍សម្រាប់តែ ខ្លួនគេ ក្រុមគ្រួសារគេ វង្សត្រកូលគេ បក្សពួកគេ និង ចៅហ្វាយនាយរបស់គេដែលជាពួក បរទេស តែប៉ុណ្ណោះ ។*

ក្នុងបច្ចុប្បន្នកាល ប្រជាជាតិខ្មែរយើងស្ទើតែទាំងអស់ មានជីវិតរស់នៅលើលោកយើងនេះ ប្រៀប បាននឹងសត្វតិរច្ឆាន គ្មានសិទ្ធិ គ្មានសេរីភាព គ្មានភាពថ្លៃថ្នូរជាមនុស្ស ត្រូវបានគេរំលោភបំពាន គំរាមកំហែង ជិះជាន់ សង្កត់សង្កិន បណ្តេញចេញ និង សម្លាប់យ៉ាងឃោរឃៅព្រៃផ្សៃជាទីបំផុត ។

ជាការពិតណាស់ក្នុងមួយរយៈពេលកន្លងមក ប្រជាជាតិខ្មែរយើង បានរួមដៃ រួមសាមគ្គីគ្នា ព្យាយាមរើបំរះខ្លួន ម្តងហើយម្តងទៀត ដើម្បីចេញអោយផុតពីក្រញាំអំណាចនៃពួកកុម្មុយនិស្ត អាយ៉ងកញ្ជះយួន

ដូចដែលបងប្អូនជនរួមជាតិខ្មែរយើងគ្រប់ៗគ្នា បានដឹង បានឮ និង បានជ្រាបរួចមកហើយថា ក្នុងរយៈ ពេល 20 ឆ្នាំកន្លងមកនេះ ប្រជាជាតិខ្មែរយើងបានធ្វើការរើបំរះចេញពីរបបអាយ៉ងកញ្ជះយួន ហ៊ុន សែន នេះមានចំនួន 04 ដងរួចមកហើយគឺ ៖

1- **ការបោះឆ្នោតជាសាកល ដោយសេរី និង យុត្តិធម៌ កាលពីថ្ងៃទី 21 ខួសភា ឆ្នាំ1993** គឺបាន សម្តែងអោយ **ពិភពលោកទាំងមូលឃើញយ៉ាងច្បាស់ថា ប្រជាជាតិខ្មែរយើងលែងត្រូវការរស់នៅ** ក្រោមការគ្រប់គ្រង របស់ គណបក្ស ប្រជាជនកម្ពុជា ដែលមានយួនកុម្មុយនិស្តក្រុងហាណូយជាម្ចាស់តទៅទៀតហើយ ។

2- **ការដង្ហែរក្បួនបាតុកម្មអហិង្សាដ៏ធំមួយ** ដែលដឹកនាំដោយលោក **សម រង្ស៊ី ប្រធានគណបក្សជាតិខ្មែរ** នាពេលនោះ នៅមុខរដ្ឋសភាជាតិ កាលពីថ្ងៃទី 30 ខែមិនា ឆ្នាំ 1997 ដែលបណ្តាលអោយមានមនុស្ស ស្លាប់ចំនួនយ៉ាងតិច 16 នាក់ និង របួសចំនួនយ៉ាងតិចក៏ 150 នាក់ ដោយអំពើឧក្រិដ្ឋគប់គ្រាប់បែកដៃជាច្រើនគ្រាប់ មកលើហ្វូងបាតុករ ដែលទាមទារអោយមានការកែទម្រង់ប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជាយើង ។

3- **ការប្លន់អំណាចពីប្រជាជន** ដែលមានការដឹកនាំដោយផ្ទាល់ពី**ឧក្រិដ្ឋជន ហ៊ុន សែន** ដើម្បី **ធ្វើរដ្ឋប្រហារបង្ហូរឈាមមួយដែលប្រព្រឹត្តិឡើងកាលពីថ្ងៃទី 5- 6 ខែកក្កដា ឆ្នាំ1997** ជាហេតុបណ្តាលអោយមានការកាប់សម្លាប់សមាជិកគណបក្ស(FUNCINPEC)និងគណបក្ស(ស៊ឺន សាន)ទាំងអ្នកនយោបាយ ទាំងកងកម្លាំងប្រដាប់អាវុធ អស់ជាច្រើនរយនាក់ រួមទាំងមានការបាត់ខ្លួនមួយចំនួនធំទៀត ដែលយើងជឿជាក់ថាពិតជាត្រូវបានពួកជនឧក្រិដ្ឋទាំងនោះសម្លាប់ចោលអស់ទៅហើយ ។

4- ការធ្វើបាតុកម្មប្រឆាំង និង មិនទទួលស្គាល់នូវ លទ្ធផលនៃ **ការប្លន់យកសន្លឹកឆ្នោត** ដ៏គួរ អោយស្អប់ខ្ពើម ជាទីបំផុតមួយទៀតពីសំណាក់**គណបក្សប្រជាជនកម្ពុជា** កាលពីថ្ងៃ 23 ខែសីហា ឆ្នាំ1998។

ប៉ុន្តែការរើបំរះគ្រប់ពេលត្រូវបានទទួលតែការ បរាជ័យ និង ការកាប់សម្លាប់ យ៉ាងព្រៃផ្សៃ ដោយមានការនិយាយ និង គំរាមបែបចំអកឡកឡើយជាញយៗពីសំណាក់ ជនកុម្មុយនិស្តផ្តាច់ការ ឈ្មោះ **ហ៊ុន សែន ហៅ( ណាល់ )** ថា ( **បើហ៊ានធ្វើហ៊ានស្លាប់** ) ។

**សួរថា តើវាមានមូលហេតុអ្វីដែលជាហេតុបណ្តាលអោយជាតិខ្មែរយើងទទួលបានតែការបរាជ័យជារៀងរហូត ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ?**

**ចម្លើយគឺវាមានមូលហេតុធំៗចំនួន 06 ប្រការដូចខាងក្រោមនេះ ៖**

ប្រការទី 1៖ មកតែអំពីស្តេចកុម្មុយនិស្ត នរោត្តម សីហនុ ត្រូវការបង្កើតឡើងវិញនូវ របបរាជានិយម ជាថ្មីម្តងទៀតឬហៅថា របបរាជានិយមទី2 ហ្នឹងហ្មែងដោយបានខ្ចីដៃពួកជនកុម្មុយនិស្តខ្ញុំកញ្ជះយួន ហ៊ុន សែន-ជា ស៊ីម ហេង សំរិន និង គណបក្សប្រជាជនកម្ពុជា ដើម្បីធ្វើរហូតបានសម្រេចជាស្ថាពរនៅឆ្នាំ 1993 ។

ប្រការទី 2 ៖ មកតែអំពីស្តេចកម្មុយនិស្ត *នរោត្តម សីហានុ* ដែលមាន*បំណងអាក្រក់ចំពោះជាតិមាតុភូមិ* យើង និង ដើម្បីជួយអោយបាន *ដល់ពួកកម្មុយនិស្តខ្មែរ ទាំងពួកខ្ញុំកញ្ជះចិន ទាំងពួកខ្ញុំកញ្ជះយួន ដែលធ្លាប់បានធ្វើជាកូនចៅខ្លួន និង ធ្លាប់បានធ្វើជាសត្រូវខ្លួន កន្លងមកអោយនៅរស់រាន និង មានអំណាចជានិរន្តរ៍ នៅលើមាតុប្រទេសដែលជាទីស្រឡាញ់នៃយើងគ្រប់ៗគ្នា ។*

ប្រការទី 3 ៖ មកតែអំពីស្តេចកម្មុយនិស្ត *នរោត្តម សីហានុ* ដែលមាន *បំណងអាក្រក់ចំពោះជាតិមាតុភូមិ* យើង និង ជាការចាំបាច់បំផុតត្រូវតែជួយរដ្ឋាភិបាលចិនកម្មុយនិស្តក្រុងប៉េកាំងដើម្បី*យកប្រទេសកម្ពុជា យើង ធ្វើជាមូលដ្ឋានទ័ព ជើងទឹក នឹង ជើងអាកាស ដ៏ធំមួយនៅក្នុងទ្វិបអាស៊ីអាគ្នេយ៍យើងនេះនាពេលអនាគត់ ។*

*ប្រការទី 4 ៖ មកតែអំពីស្តេចកម្មុយនិស្ត នរោត្តម សីហានុ មានបំណងប្រាថ្នា រក្សា ការពារ អំណាច និង រាជបល្ល័ង្ក នៃរបបរាជានិយមទី2 នេះ ទុកអោយកូនប្រុសសំណប់របស់ ម៉ូនិក សីហានុ ដែលមានឈ្មោះថា នរោត្តម សីហាមុនី ហ្នឹងឯង នៅក្រោយពេលខ្លួនស្លាប់ ប៉ុន្តែជាអកុសលខ្លួនមិនទាន់ស្លាប់ ស្រាប់តែយួនប្លន់យកជាមុន ៖*

*ប្រការទី 5 ៖មកតែអំពីស្តេចកម្មុយនិស្ត នរោត្តម សីហានុ ដែលមាន បំណងអាក្រក់ចំពោះជាតិមាតុភូមិ យើង និង ជាការចាំបាច់ត្រូវតែ ទប់ស្កាត់ និង ការពារ អោយបានជាស្ថាពរនៅការបង្កើតឡើងវិញជាថ្មីនូវ របបសាធារណរដ្ឋសេរី និង របបប្រជាធិបតេយ្យសេរីពិត នៅក្នុងប្រទេសកម្ពុជានាពេលខាងមុខ ។*

*ប្រការទី 6 ៖ មកតែអំពីស្តេចកម្មុយនិស្ត នរោត្តម សីហានុ* ***(ចាញ់បោកយួន )****ជាថ្មីម្តងទៀត ហើយការចាញ់លើកនេះគឺ* ***(ចាញ់ស្លាប់ )*** *ដែលខ្មែរយើងតែងតែហៅថាជន* ***(អស់លក្ខណ៍ )*** *ហ្នឹងហ្មែង ។*

**ខាងក្រោមនេះយើងនឹងនិយាយអំពី ជោគវាសនា និង អនាគត់ របស់ជាតិ មាតុភូមិកម្ពុជាវិញម្តង ។**

*ដោយកំពុងមើលឃើញយ៉ាងច្បាស់នូវ មហិច្ឆតា ល្មោភ លោភលន់ ឥតឈប់ឈរពីសំណាក់សត្រូវ យួនឈ្លានពាន ក្នុងការលេបបំបាត់ និង ដណ្តើមយកជាតិមាតុភូមិកម្ពុជាយើងទៅធ្វើជារបស់គេ នាពេលខាងមុខ ដូច្នេះយើងសូមធ្វើការបំភ្លឺត្រួសៗដូចខាងក្រោមនេះ ៖*

មានបញ្ហាធំៗចំនួន 03 ដែលអ្នកនយោបាយខ្មែរគ្រប់និន្នាការ និង ជាតិខ្មែរទាំងមូលត្រូវតែដឹង នឹង ត្រូវតែរួបរួមគ្នាធ្វើ រួបរួមគ្នាដោះស្រាយជា បន្ទាន់ និង បន្ទាន់ ដោយមិនអាចបង្អង់យូរបានតទៅទៀតទេ នាពេលនេះគឺ ។

1- បញ្ហាអន្តោប្រវេសន៏យួនទាំងខុសច្បាប់ និង ស្របច្បាប់ ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។

2- បញ្ហាការធ្វើសមាហរណកម្មអាស៊ាននាឆ្នាំ 2015 ខាងមុខនេះ ។

3- បញ្ហាការបោះឆ្នោតតាមរបបប្រជាធិបតេយ្យ នៅក្នុងប្រទេសដែលគ្មានប្រជាធិបតេយ្យ ។

## 1- បញ្ហាអន្តោប្រវេសន៏យួន ៖

*បញ្ហាអន្តោប្រវេសន៍យួននេះ គឺជាបញ្ហាធំបំផុត និង ជាបញ្ហាស្លាប់រស់ សម្រាប់ ជាតិនិងមាតុភូមិ កម្ពុជាយើងនាពេលដ៏ខ្លីខាងមុខនេះ ដែលខ្មែរគ្រប់និន្នាការនយោបាយត្រូវតែរួមគ្នាដោះស្រាយជាបន្ទាន់ ។*

*រដ្ឋាភិបាលយួនកម្មុយនិស្តក្រុងហាណូយមិនអាចយកជ័យជំនះតាមយុទ្ធសាស្ត្រនៃការបោះឆ្នោតលើជាតិខ្មែរយើងបានទេ បើយើងជាខ្មែរគ្រប់និន្នាការនយោបាយ ខ្មែរគ្រប់ភាគីដែលពាក់ព័ន្ធ ចេះយោគយល់គ្នាចេះជួយ គ្នា ចេះរួបរួមគ្នាអោយបានជាស្ថាពរនូវកម្លាំងជាតិពិតប្រាកដមួយនោះ ។*

តើយួនគេអាចយកឈ្នះលើជាតិខ្មែរយើងដោយមិនចាំបាច់ប្រើប្រាស់កម្លាំងទ័ពតាមរបៀបដូចម្តេច ? ហើយចុះចំណែកខ្មែរយើងវិញ តើអាច ទប់ស្កាត់ នូវគំនិតដ៏សែន ល្មោភ លោភលន់ របស់សត្រូវយួនដែលជា សត្រូវស៊ីពូជរបស់ខ្មែរយើង តាមរបៀបដូចម្តេច ? ។

យួនគេអាចយកឈ្នះលើជាតិខ្មែរយើងដោយ ៖

*1-អន្តោប្រវេសន៍យួនដែលបានចូលមករស់នៅរួចជាស្រេចហើយក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ គឺមានចំនួនយ៉ាងតិច ប្រាំលាននាក់(5.000.000) ហើយជនជាតិយួនទាំងនោះចំនួនយ៉ាងតិច 80% បានទទួល*

សញ្ជាតិជាពលរដ្ឋខ្មែរដោយស្របច្បាប់ និង បានទទួលប័ណ្ណបោះឆ្នោតរួចរាល់ហើយដែរ ។

2-អន្តោប្រវេសន៍យួន ទាំងអស់ដែលបានចូលមករស់នៅ ក្នុងប្រទេសកម្ពុជាយើង ចាប់ពីឆ្នាំ1979 រហូតដល់ឆ្នាំ1985 គឺ 90% ជាកងកម្លាំងប្រដាប់អាវុធ និង កម្លាំងចារកម្ម ។ល។និង។ល។ ហើយចាប់តាំង ពីឆ្នាំ 1985 រហូតមកដល់សព្វថ្ងៃនេះ ពួកយួនទាំងនោះបានបង្កើត ជាសមាគម ជាសហគម ជាសហគ្រាស គ្រប់ខែត្រ ក្រុង របស់ខ្មែរយើងទាំង 21 ។

គឺពួកគេបាន រៀបចំរចនាសម្ព័នគ្រប់គ្រងជនជាតិយួនទាំងអស់ក្នុងប្រទេសកម្ពុជាយើងប្រៀបដូច ជារចនាម្ព័នកងទ័ព ដើម្បីជាប្រយោជន៍ ងាយស្រួលក្នុងការគ្រប់គ្រង និង បញ្ជាការ ជាពិសេសបំផុតនោះ គឺ ដើម្បី ចាត់ចែង និងសម្រួលដោះស្រាយ បញ្ហាផ្សេងៗជាមួយ អាជ្ញាធរខ្មែរយើងក្នុងការ សុំចូលសញ្ជាតិជាខ្មែរ និង សុំប័ណ្ណ បោះឆ្នោត ជាដើម ។

3-រដ្ឋាភិបាលយួន ក្រុងហាណូយ បានបន្ត បញ្ជូន និង បញ្ចូល បន្ថែមនូវអន្តោប្រវេសន៍យួនមកក្នុង ប្រទេសរបស់យើងដើម្បីអោយបានគ្រប់ចំនួន 2/3 នៃចំនួនអាសនៈក្នុងរដ្ឋសភាជាតិខ្មែរយើងនាពេលអនាគត់ ។

4- ជាតិខ្មែរទាំងមូល ទាំងស្តេច ទាំងមន្ត្រី ទាំងរាស្ត្រ ទាំងរាជការ ពួកគេគិតតែពីរឿងការដណ្តើម អំណាច ដណ្តើមផលប្រយោជន៍ សម្រាប់តែខ្លួនគេ ក្រុមគ្រួសាគេ វង្សត្រកូលគេ បក្សពួកគេ និងមិនត្រឹមតែប៉ុណ្ណឹង ទេ ពួកគេថែមទាំង យកផលប្រយោជន៍ដ៏មហាសាលរបស់ជាតិយើង យកទៅបំរើ យកទៅ ផ្គត់ផ្គង់ ដល់ចៅហ្វាយ នាយ របស់ពួកគេដែលជាពួកបរទេសដូចជា ចិន-យួន-បារាំង-អាមេរិកាំង-សៀម ។ល។និង។ល។ ។

ជានិច្ច ជាកាល ម្តងហើយ ម្តងទៀត នៅពេលណាដែលមេដឹកនាំខ្មែរយើងដែលជាអាយ៉ងខ្ញុំកញ្ជះ បរទេស ទាំងឡាយ ទាំងពួង គេឈ្លោះគ្នា ព្រោះតែ គេបែងចែកអំណាច បែងចែកផលប្រយោជន៍គ្នា មិនត្រូវ ពួក គេ ក៏តាំងខ្លួនគេជា អ្នកដឹកនាំ រួចហើយចាប់ផ្តើម រត់ត្របាញ់ជើង សំដៅទៅរកប្រជាពលរដ្ឋ ដើម្បីអោយជួយពួកគេ ដោយចាប់ផ្តើម ស្រែក ជំទាលក្តែងៗថាខ្លួន ជាអ្នក ស្នេហាជាតិៗ ជាអ្នក សង្គ្រោះជាតិៗ ជាអ្នក រំដោះជាតិៗ ជាអ្នក ស្រោចស្រង់ជាតិៗ ដល់តែមាន អ្នកស្នេហា អ្នកសង្គ្រោះ អ្នករំដោះ អ្នកស្រោចស្រង់ ស្អីៗច្រើនហួសពេកទៅ ជាតិ និង មាតុភូមិ ដែលជាទីស្រឡាញ់នៃយើងគ្រប់ៗគ្នា ( ជិតស្លាប់ហើយ ) ។

បី ទសវត្សរ៍ចុងក្រោយនេះ ប្រទេសខ្មែរយើង និង ប្រជាជាតិខ្មែរយើង គ្មានការអភិវឌ្ឍន៍ គ្មានការ រីកចំរើន លូតលាស់ អ្វីបន្តិចសោះឡើយ ផ្ទុយទៅវិញ ពួកគេរិតតែ រហេមរហាម គ្រីក្រគោកយ៉ាក លំបាកវេទនា រកទីបំផុតគ្មាន ចំណែកពួកគេដែលជាមេដឹកនាំងណោះវិញគឺគេមានគ្រប់បែបយ៉ាងមានទាំងអំណាចមានទាំងលុយ កាក់ មាសប្រាក់កែវកង ដំបងពេជ្រ បរិវារឆ្វេងស្តាំ មហាភូមិគ្រឹះ មហាព្រះរាជតំណាក់ មហាព្រះបរមរាជវាំង រហូត អ្នកខ្លះមានច្រើនហួសពេក ច្រើនរហូតដល់ ចង់ក្លាយខ្លួនទៅជាម្ចាស់ផ្តាច់មុខ នៃ ជាតិ និង មាតុភូមិ កម្ពុជាយើងទាំង មូលតែម្តង ចំណែកឯអ្នកខ្លះវិញនោះ មានច្រើនហួសពេក ក្លាយខ្លួនទៅជាមនុស្ស ឆ្កួត លង់ទ្រនេស លែងស្គាល់ ឪពុក លែងស្គាល់បង លែងស្គាល់ប្អូន ។ល។ និង ។ល។

5-នាបច្ចុប្បន្នកាលនេះប្រជាពលរដ្ឋខ្មែរយើងចំនួន 60% មិនបានគិតដល់រឿងបោះឆ្នោតស្អីនោះ ទេពួកគាត់គិតតែពីរឿងជិវិតប្រចាំថ្ងៃ( ក្រពះ )ពួកគាត់តែងតែនិយាយថាមិនទៅបោះឆ្នោតទេព្រោះវានាំអោយខូច ពេល ខូចវេលា ដើម្បីរកស៊ីរបស់ពួកគាត់ ពីព្រោះពួកគាត់យល់ឃើញថា បោះឆ្នោតអោយ គណបក្សណា ក៏ដូច គណបក្សណាដែរ គឺគ្មានផលប្រយោជន៍អ្វីសូម្បីតែបន្តិចអោយដល់ពួកគាត់ឡើយ រួមផ្សំទាំងការលំបាក ក្នុងការធ្វើ ដំណើរ ព្រមទាំងការសោងគ្រប់បញ្ហា ដើម្បីជា ឧបសគ្គសម្រាប់ពួក គាត់ ពីសំណាក់សមាជិក សមាជិកា គណបក្ស ប្រជាជនកម្ពុជា ក្នុងគោលដៅរាំងមិនអោយពួកគាត់ទៅបោះឆ្នោត បើប្រសិនជាគេដឹងថាអ្នកនោះ និងបោះអោយ គណបក្សផ្សេង ។

6-ចំណែក ពួកជនជាតិយួនវិញគេគិតថាការបោះឆ្នោត គឺជាកត៌ព្វកិច្ចដ៏ធំធេងណាស់សម្រាប់ពួកគេ ដែលត្រូវតែ

**អនុវត្តន៍ដោយខកខានមិនបាន ហើយនៅពេលមានការបោះឆ្នោតម្តងៗ បើសិនជាពួកគេអាចបោះបាន លើសពីមួយដង ពួកគេនឹងធ្វើឆ្លាមឥតរុញរាឡើយ គឺវាមានការផ្តួយស្រឡះពីប្រជាពលរដ្ឋខ្មែរយើងដែលជាម្ចាស់ពិត នៃ អ័ព្ភវាសនា និង អនាគត់ របស់ជាតិមាតុភូមិកម្ពុជា ។**

*សារៈដ៏សំខាន់ទាំង 07 ប្រការខាងលើនេះ គឺប្រៀបបីដូចជា ជម្ងឺមហារីក ដ៏កាចសាហាវដែលកំពុងយាយយី បំផ្លិចបំផ្លាញ បេះដូង របស់ជាតិខ្មែរយើងក្នុងពេលបច្ចុប្បន្នហើយវានឹងធ្វើអោយជាតិយើង(ស្លាប់ បាត់បង់) នាពេលខាងមុខនេះ ។*

## 2- បញ្ហាការធ្វើសមាហរណកម្មអាស៊ាននាឆ្នាំ2015 ៖

បញ្ហាការធ្វើសមាហរណកម្មអាស៊ាននាឆ្នាំ2015 ខាងមុខនេះ សម្រាប់ប្រទេសកម្ពុជាយើងៗមើលឃើញយ៉ាងច្បាស់នូវគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរដែលជាតិខ្មែរយើងទាំងមូលមិនអាច *ការពារនិងទប់ស្កាត់* បានឡើយ

**ព្រោះហេតុអ្វីបានជាយើងហ៊ាននិយាយដូច្នេះ ?**

*ព្រោះថាប្រជាជាតិខ្មែរយើងស្ទើតែទាំងអស់អ្នកដែលមានវ័យចាប់ពី 18 ឆ្នាំដល់ 60 ឆ្នាំ និងធ្វើចំណាកស្រុក ដើម្បី រកការងារធ្វើ និង ធ្វើការផ្លាស់ប្តូរទីលំនៅជាអចិន្ត្រៃយ៍ នៅលើទឹកដីនៃប្រទេសមួយដែល ពួកគេជឿថាអាចរក សុភមង្គលល្អ ជូនដល់ក្រុមគ្រួសារពួកគេបាន ពួកគេ និង មិនវិលត្រឡប់ចូលទៅរស់នៅក្នុងប្រទេស កម្ពុជាយើងវិញឡើយ ដ៏រ៉ាបណាប្រទេសខ្មែរយើងគ្មានការគ្រប់គ្រងតាមបែបបទប្រជាធិបតេយ្យសេរីពិតប្រាកដទេនោះ ។*

*យួនកម្មុយនិស្ត ក្រុងហាណូយ បានឱកាសល្អ និង ស្របច្បាប់របៀបនេះ គេពិតជា នឹង បញ្ជូលនិគមន៍ជនជាតិយួន 05 ឬ 10 លាននាក់ មកក្នុងប្រទេសកម្ពុជាយើងបន្ថែមទៀត ដើម្បីគម្រប់សន្លឹកឆ្នោត 2/3 នៃអាសនៈក្នុងរដ្ឋសភាខ្មែរយើងក្នុងអំឡុងការបោះឆ្នោតនាឆ្នាំ 2018 ខាងមុខនេះ សួរថា* ***តើវានឹងមានហេតុការណ៍អ្វីខ្លះ កើតមានឡើងមកលើ ជាតិ និង មាតុភូមិកម្ពុជា យើងនាពេលនោះ ? ។***

## 3- បញ្ហាការបោះឆ្នោតតាមរបបប្រជាធិបតេយ្យ ៖

*បញ្ហាការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស នេះហើយដែលជាមូលហេតុដ៏ធំមួយធ្វើអោយ ជាតិ និង មាតុភូមិកម្ពុជាយើង ទទួលរងនូវគ្រោះមហន្តរាយ និង រលាយបាត់រូបជាស្ថាពរនាពេល អនាគត់ ។*

*លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស នេះជាយុទ្ធសាស្ត្រថ្មីមួយដែលសត្រូវយួនឈ្លានពានក្រុងហាណូយមិនចាំបាច់បញ្ជូនកម្លាំងទ័ពអោយចូលមក រុករានឈ្លានពាន ដណ្តើមយកដូចកាលមុនៗ នោះទៀតទេ ប៉ុន្តែគេប្រើយុទ្ធសាស្ត្រនៃការបោះឆ្នោតនេះវិញក្នុងការយកឈ្នះដោយសំអាងទៅលើកម្លាំងមនុស្សជាកម្លាំងសន្លឹកឆ្នោតហើយគេបាន ចាប់ផ្តើមប្រើប្រាស់ យុទ្ធសាស្ត្រនេះតាំងតែការបោះឆ្នោតនៅឆ្នាំ1993 មកម្ល៉េះ ។*

*យុទ្ធសាស្ត្រ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនេះនិងធ្វើអោយយួនសញ្ជាតិខ្មែរមានលទ្ធភាពត្រួតត្រា និង កាន់កាប់ អំណាចរដ្ឋ ពិតប្រាកដនៅក្នុងប្រទេសកម្ពុជាយើងយ៉ាងងាយស្រួលជាទីបំផុត ព្រោះថានៅពេលណាដែលសត្រូវយួនគេមើលឃើញថា ពួកគេមានកម្លាំងគ្រប់គ្រាន់ ដើម្បីបោះឆ្នោតទៅឈ្នះពួកគេនឹងបង្កើតគណបក្សថ្មីមួយ ឬ ពីរ ដើម្បីចូលរួមប្រណាំងប្រជែងដណ្តើមសន្លឹកឆ្នោតតាមរដ្ឋធម្មនុញ្ញខ្មែរយើង ។*

*នាបច្ចុប្បន្នកាលនេះ ពួកយួនសញ្ជាតិខ្មែរទាំងនោះគេនាំគ្នា បោះឆ្នោតអោយគណបក្សប្រជាជនកម្ពុជាហើយសន្លឹកឆ្នោត របស់ពួកគេដែល គណបក្សប្រជាជន បានទទួលកាលពីឆ្នាំ2008 កន្លងមកនេះមិនតិច ជាង 50 អាសនៈក្នុងរដ្ឋសភាឡើយ ដូច្នេះបើ05 ឬ 10 ឆ្នាំទៅមុខទៀតសន្លឹកឆ្នោតរបស់ពួកគេអាចឡើងទៅដល់80 អាសនៈសភា* **សួរថាតើ ជោគវាសនា និង អនាគត់ របស់ ជាតិមាតុភូមិយើងវាទៅជាយ៉ាងណា ? ។**

*ដូច្នេះ បើយើងគិតលេងៗទៅឃើញថា យួនគេទទួលបាន 80 អាសនៈ គណបក្ស ប្រជាជនកម្ពុជា*

ទទួលបាន 30 អានៈ បូកបញ្ចូលគ្នាបាន 110 អាសនៈ គឺយួនជាអ្នកគ្រប់គ្រងរដ្ឋសភា និង ជាអ្នករៀបចំរដ្ឋភិបាលខ្មែរយើងមិនមែន **គណបក្សប្រជាជន និង ហ៊ុន សែន ទៀតទេ ។**

**បើយួនមានសិទ្ធិ មានអំណាចកាន់កាប់ត្រួតត្រាលើខ្មែរយើងដោយស្របច្បាប់តាមរដ្ឋធម្មនុញ្ញ តើយួន និង ធ្វើអ្វីខ្លះ ?**

**រឿងនេះ យើងអាចមើលឃើញត្រួសៗដូចខាងក្រោមនេះ ៗ**

1- នាយករដ្ឋមន្ត្រី និង សមាជិករដ្ឋាភិបាល 70% ពិតជាយួនសញ្ជាតិខ្មែរយ៉ាងពិតប្រាកដ ។

2- គ្រប់ស្ថាប័នរដ្ឋសំខាន់ៗរបស់ជាតិខ្មែរយើង 70% ពិតជាយួនសញ្ជាតិខ្មែរយ៉ាងពិតប្រាកដ ។

3- បញ្ចូលនិគមន៍ជនជាតិយួន 10 ទៅ 20 លាននាក់ទៀតមកក្នុងកម្ពុជា ។

4- មិនបញ្ចូល កម្ពុជា ទៅក្នុងប្រទេសវៀតណាមដូច កម្ពុជាក្រោមទេ ។

5- មិនអោយមានការជិះជាន់សង្កត់សង្កិនមកលើជនជាតិខ្មែរដូច ខ្មែរកម្ពុជាក្រោមឡើយ ដោយសំអាងទៅលើហេតុថា របបគ្រប់គ្រងកម្ពុជាបច្ចុប្បន្នជារបបប្រជាធិបតេយ្យ អាស្រ័យច្បាប់ ។

6- បញ្ចុះបញ្ចូល ញុះញង់ អោយខ្មែរ និង ខ្មែរឈ្លោះគ្នា បែកបាក់គ្នា កាប់សម្លាប់គ្នា ស្អប់ខ្ពើមគ្នា ជារឿយៗ ហើយធ្វើអោយមានជនជាតិយួនជាអ្នកជួយ ជាអ្នកដោះស្រាយវិបត្តផ្សេងៗ។ល។និង។ល។

យុទ្ធសាស្ត្រ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនេះបានធ្វើអោយយួនកុម្មុយនិស្ត ក្រុងហាណូយ ទទួលបានជោគជ័យយ៉ាងត្រចះត្រចង់លើ ជាតិខ្មែរយើងទាំងស្រុងនូវ រាល់ការបោះឆ្នោតទាំងការបោះឆ្នោត ឃុំ សង្កាត់ រហូតដល់ការបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រ ដូចដែលខ្មែរយើងគ្រប់ៗគ្នាបានដឹងរួចមកហើយ ៗ **( យុទ្ធសាស្ត្រនេះនិងធ្វើអោយខ្មែរយើងស្លាប់ដាច់ពូជ )ៗ**

ដូច្នេះចាប់ពីថ្ងៃនេះតទៅខ្មែរ គ្រប់និន្នាការនយោបាយ ត្រូវតែ ឈប់ឈ្លោះគ្នា ឈប់កាប់សម្លាប់គ្នា ដើម្បីពួកបរទេសតទៅទៀត សូមខ្មែរទាំងអស់ទាំងក្នុងនិងក្រៅប្រទេសមេត្តារួបរួមគ្នា អោយបានជាកម្លាំងអ្នកស្នេហាជាតិពិតប្រាកដមួយ ដើម្បីទប់ស្កាត់អោយបានទាន់នូវ មហិច្ឆតា លោភលន់ និង លេបបំបាត់ពូជសាសន៍ខ្មែរយើងនាពេលខាងមុខ ។

យើងទាំងអស់គ្នាជាជាតិខ្មែរ យើងជាខ្មែរម្ចាស់ស្រុក ជាម្ចាស់នៃ ជោគវាសនាជាតិ ដូច្នេះ អ្វីៗទាំងអស់ត្រូវតែយើងគឺជាអ្នកកំណត់ មិនមែនយួនជាអ្នកកំណត់ទេ ហើយបើយើងមិននាំគ្នាធ្វើ មិននាំគ្នាដោះស្រាយនៅពេលនេះទេគឺ បញ្ហា អន្តោប្រវេសន៍យួននេះហើយគឺ ជាសេចក្តីប្រម៉ាតដ៏មហន្តរបស់ជាតិខ្មែរយើងទាំងមូល ខ្មែរយើងកំពុងបំភ្លេចពាក្យចាស់មួយឃ្លា ដែលលោកតែងតែដាស់តឿនយើងជារឿយៗថា **សេចក្តីប្រម៉ាតនាំមកនៅសេចក្តីវិនាស សេចក្តីប្រម៉ាតនៅទីណា សេចក្តីវិនាសនៅទីនោះ ៗ**

**ថ្ងៃនេះយើង ខេម រិន្ទ បានសរសេរសេចក្តីរំលឹកមួយច្បាប់នេះ ឡើងមកដើម្បី** អោយលោក ហ៊ុន សែន ដែលមានមុខតំណែងជា នាយករដ្ឋមន្ត្រី ជាប្រមុខរដ្ឋាភិបាលខ្មែរ ទោះបីជាមុខតំណែងរបស់ លោកហ្នឹងបានមកដោយការ លួច និង ប្លន់ ក៏ដោយចុះ ប៉ុន្តែរឿងដែលសំខាន់បំផុតនោះគឺ លោកកំពុងតែដឹកនាំរដ្ឋខ្មែរទាំងមូលឆ្ពោះទៅរក គ្រោះមហន្តរាយ ដែលមិនអាចជៀសផុតបាននោះ ដូច្នេះលោកត្រូវតែត្រេះរិះពិចារណាអោយបានល្អិត ល្អន់ និង ទាន់ពេលវេលា ។

លោក ហ៊ុន សែន លោកជាកូនខ្មែរពិតប្រាកដណាស់ ព្រោះយើងមិនដែល ឮ ខ្មែរយើងណាគេនិយាយថា លោកជាជនជាតិយួននោះទេ ក៏ប៉ុន្តែយើងបាន ឮ ជារៀងរាល់ថ្ងៃ រាល់ខែ និង រាល់ឆ្នាំ ថាលោកជាខ្មែរ តែជាខ្មែរ ដែលកំពុងធ្វើ ខ្ញុំកញ្ជះយួនកុម្មុយនិស្ត និង កញ្ជះចិនកុម្មុនិស្ត ដូច្នេះលោក ហ៊ុន សែន ខ្លួនឯងក៏ពិតជាបានយល់ និង ដឹងច្បាស់ហើយ នៅអ្វីខ្លះ ដែលនឹងធ្វើអោយជាតិមាតុភូមិកម្ពុជាយើងនៅ មានជីវិតជានិរន្តរ៍ ឬ មានគ្រោះថ្នាក់ រហូតបាត់បង់ជារៀងរហូតនោះ ។

យើងជឿជាក់ថាលោកគ្មានលទ្ធភាពនឹងធ្វើការទប់ស្កាត់ ឬ ការពារបានទេ បើលោក និង បរិវាររបស់លោកនៅតែបន្តកាន់កាប់អំណាចក្រោមឥទ្ធិពលរបស់សត្រូវយួនក្រុងហាណូយតទៅមុខទៀតនោះ។

សេចក្តី ក្រើនរំលឹករបស់យើងច្បាប់នេះ ពិតជាមិនធ្វើអោយលោក និង បក្សពួករបស់លោក ដែលជាជន កំហូច ខឹលខូច គ្មាននរណាប្រៀបនោះ ព្រឺរោម ឬ ព្រឺខ្លាច ហើយភ្ញាក់ពីក្តីស្រមើលស្រម៉ៃថា ខ្លួន និង កាន់កាប់ អំណាចផ្តាច់ការ និង ផ្តាច់មុខ អស់មួយពូជរបស់ពួកលោកបានទេ ។

ប៉ុន្តែ ក្នុងនាមលោកជា នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ជាប្រទេសមួយ ដែលធ្លាប់ តែមាន វឌ្ឍនធម៌ និង អរិយធម៌ ខ្ពង់ខ្ពស់ មានកេរ៍ឈ្មោះល្បីល្បាញទូទាំងពិភពលោក ហើយបច្ចុប្បន្នកាលនេះប្រទេសកម្ពុជា យើងកំពុងស្ថិតនៅក្នុងក្របខ័ណ្ឌពិភពលោកមិនមែនស្ថិតនៅជាប្រទេសឯកោឯកាដូចកាលពី100ឆ្នាំមុននោះទៀត

សូមលោក និង បរិវារ របស់លោកក្រឡេកមើលក្រោយ មើលអតីតកាល អោយបានច្បាស់ នូវប្រវត្តិសាស្ត្រពិតរបស់ពួករាជានិយម និង ពួកផ្តាច់ការនិយម មួយចំនួនដែលមាននៅលើលោកកន្លងមក ថាតើពួក គេទាំងនោះអាចរក្សានិងការពារអំណាចផ្តាច់ការនិងផ្តាច់មុខអោយនៅគង់វង្សស្ថិតស្ថេរចិរកាលជានិរន្តរ៍បានដែរឬអត់

អ្វីៗទាំងអស់ដែលមាននៅលើលោកយើងនេះ ត្រូវតែមានការផ្លាស់ប្តូរទៅតាមច្បាប់ធម្មជាតិ ច្បាប់ជាតិ និង ច្បាប់អន្តរជាតិ គ្រាន់តែវា ផ្លាស់ពីល្អទៅអាក្រក់ ឬ ផ្លាស់ពីអាក្រក់ទៅល្អ វិញតែប៉ុណ្ណឹង មនុស្សយើងក៏ អញ្ចឹងដែរ កើត ចាស់ ឈឺ ស្លាប់ គ្មានបុគ្គលណា ឬ ស្តេចណា ហាមឃាត់បានឡើយ សូម្បីតែ ព្រះពុទ្ធ ជាអម្ចាស់ ដែលជាព្រះបរមគ្រូ នៃ យើង ក៏លោកមិនអាចធ្វើបានដែរ ឬ **លោកអាចធ្វើបាន ? លោក ហ៊ុន សែន** ។

យ៉ាងណាមិញ អំណាចក៏អញ្ចឹងដែរ អំណាចក៏គឺអំណាច អំណាចមិនមែនជារបស់ បុគ្គលណាម្នាក់នោះឡើយ ហើយក៏គ្មានបុគ្គលណាម្នាក់អាចធ្វើជាម្ចាស់ ផ្តាច់មុខនៃអំណាចបានដែរ ក្នុងសម័យកាលសព្វថ្ងៃនេះ ជាសម័យលទ្ធិប្រជាធិបតេយ្យ អាស្រ័យដោយសន្លឹកឆ្នោត ពីប្រជាពលរដ្ឋ ដូច្នេះប្រជាពលរដ្ឋគឺជា **ម្ចាស់នៃអំណាច ពិតប្រាកដ ៗ**

**អំណាចដែលលោកមានសព្វថ្ងៃនេះ** មិនមែនបានមកដោយការលួច ការប្លន់ ទេឬ? ដូច្នេះវាងាយនឹងបាត់បង់ទៅវិញណាស់ ទោះបីជាលោក ខិតខំរក្សានិងការពារយ៉ាងណាក្តីខ្លួនលោកផ្ទាល់ក៏ដឹងច្បាស់ដែរអំពីរឿងហ្នឹង ថាលោកបានធ្វើជានាយករដ្ឋមន្ត្រីរហូតដល់សព្វថ្ងៃនេះគឺអ្នកណាជាអ្នកកំណត់អោយលោកមិនមែនគណបក្សប្រជាជនកម្ពុជាទេឬ? ហើយគណបក្សប្រជាជនហ្នឹងបានអំណាចមកពីណា មិនមែនបានមកពីយួនទេឬ ? ។

ចំណែកប្រជាជាតិខ្មែរយើងស្ទើតែទាំងអស់ គឺគ្មាន នរណាគេ ស្រឡាញ់ និង គោរព លោកទេ សព្វថ្ងៃនេះ លោកក៏ដឹងដែរ ចំពោះអ្វីៗ ដែលលោក ខំប្រឹងអួត និង ខំប្រឹងធ្វើ នាបច្ចុប្បន្ននេះ តើលោកធ្វើដើម្បីអ្វី លោកពិត ជាឆ្លើយថា ធ្វើដើម្បីជាតិ និង មាតុភូមិរបស់យើងហើយ ប៉ុន្តែការពិត មិនមែនអញ្ចឹងទេ គឺមិនមែនទាល់តែសោះ យើង សូមប្រកែកដាច់អហង្ការចំពោះរឿងនេះ ព្រោះថាអ្វីៗ ទាំងអស់ដែលលោកកំពុងតែធ្វើហ្នឹង គឺធ្វើដើម្បី រក្សា និង ការពារ អំណាចផ្តាច់ការ និង ផ្តាច់មុខ របស់លោកដែលមាននៅសព្វថ្ងៃនេះ សម្រាប់ ទុកអោយ កូន ទុកអោយ ចៅ របស់លោកហ្នឹង ។

## តើលោកអាច រក្សា និង ការពារ អំណាចដែលមាននៅក្នុងដៃរបស់លោកសព្វថ្ងៃនេះបានដោយរបៀបណា ?

បើក្នុងពេលដែលលោកកំពុងតែ រក្សា និង ការពារអំណាចហ្នឹងវាបានធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ជាតិ និង អាយុជីវិតរបស់ជាតិខ្មែរយើងជាច្រើនសន្ធឹកសន្ធាប់រាប់មិនអស់ ហើយមិនត្រឹមតែប៉ុណ្ណោះទេ សូម្បីតែ ផលប្រយោជន៍ និង អាយុជីវិតរបស់មនុស្សក្នុងគណបក្សប្រជាជនកម្ពុជាដែលមានរូបលោកជា អនុប្រធានគណបក្សហ្នឹង ក៏មានការប៉ះពាល់សម្បើមណាស់ដែរកន្លងមកនេះ។

## សួរថាតើព្រោះហេតុអ្វី ?

ព្រោះថាលោកត្រូវការអំណាចផ្តាច់មុខ ដើម្បី រក្សា និង ការពារ នូវតំណែងជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាជានិរន្តរ៍ តពូជពង្សវង្សត្រកូលរបស់លោកឯងហ្នឹង យើងសួរថាតើមានមនុស្សប៉ុន្មាននាក់ក្នុងគណបក្សប្រជាជនដែលកំពុង ស្អប់ខ្ពើមលោក ហើយរងចាំឱកាស់ដើម្បីកំចាត់ក្រុមរបស់លោក ។

នាបច្ចុប្បន្នកាលនេះមានមនុស្សទូទាំងពិភពលោក នរណាក៏គេស្អប់ គេខ្ពើមលោកដែរ ព្រោះពួកគេមើលឃើញយ៉ាងច្បាស់ថាលោកជាជនកម្មុយនិស្តមហាផ្តាច់ការ ជាជនពាល ជាជនល្ងង់ខ្លៅ ជាជន ឧក្រិត្ត ព្រៃផ្សៃ និង ជាជន ក្បត់ជាតិ មាតុភូមិ ខ្លួនឯង ។ល។ និង ។ល។

ឥឡូវនេះលោកកំពុងនឹងសម្តែងអោយភ្នែកជាតិ និង អន្តរជាតិឃើញថា លោកឯងហ្នឹងកំពុងតែឆ្កួតនឹង អំណាចយ៉ាងខ្លាំង គឺនិយាយ លែងដឹងខុស លែងដឹងត្រូវ ជាមនុស្សតទៅទៀតហើយ លោកកំពុងតែភ្លេចភ្លើចគិត ថាខ្លួនជានាយករដ្ឋមន្ត្រីនៃប្រទេសមួយដែលកំពុងមានបញ្ហាផ្ទៃក្នុងយ៉ាងធ្ងន់ធ្ងរទោះបីជាបញ្ហាទាំងអស់នោះមិនទាន់បានផ្ទុះចេញមកអោយឃើញជារូបរាងនាពេលនេះក្តី ប៉ុន្តែវាប្រៀបបានទៅនឹងរលកក្រោមទឹក គឺវាអាចនឹងផ្ទុះឡើងមកនៅពេលណាក៏បានដែរ ។

## មនុស្សម្នាក់ដែលកំពុងឆ្កួតនឹងអំណាច តើគេមានចរិត និង កាយវិការដូចម្តេចខ្លះ ?

ជានិច្ចជាកាលម្តងហើយម្តងទៀត ដែលអាយ៉ងខ្ញុំកញ្ជះចិន កញ្ជះយួន ហ៊ុន សែន តែងតែយកដៃរបស់គេដែលពោរពេញទៅដោយការ ប្រព្រឹត្តបទឧក្រិដ្ឋ ប្រព្រឹត្តអំពើក្បត់ជាតិ និង បំផ្លិចបំផ្លាញជាតិទៅ បិទបាំងមេឃ គេហ៊ានបំភ្លើសប្រវត្តិសាស្ត្រជាតិ និង ប្រវត្តិសាស្ត្រអន្តរជាតិ គេហ៊ានពន្យល់ពលរដ្ឋខ្មែរហ៊ានពន្យល់អន្តរជាតិទាំងកម្រោលប្រាំបីជ្រុង ដើម្បី អោយយល់ អោយឃើញ អោយស្តាប់ អោយឮ តាមតែពួកគេបាន ចង្អុល និង បង្ហាញប្រាប់ នូវអ្វីដែលជាគោលគំនិត និង គោលបំណងរបស់ពួកគេ។

### ឧទាហរណ៍ ៖

បើពួកគេចង្អុលទៅរក( សត្វជ្រូក) ហើយគេនិយាយប្រាប់ថាអាសត្វហ្នឹងគឺ(សត្វគោ)ហើយបើគេចង្អុលទៅរក(សត្វគោ)ហើយគេនិយាយប្រាប់ថាអាសត្វហ្នឹងគឺ(សត្វឆ្កែ) ទាំងអស់នេះគឺជារឿងពិតដែលពួកគេកំពុងតែប្រព្រឹត្តនាពេលបច្ចុប្បន្ន សកម្មភាពនេះគឺជា សណ្តានដ៏សែនមហាចង្រៃ របស់ពួកកម្មុយនិស្ត ដែលបានក្លាយទៅជា ទម្លាប់ដ៏មហាអាក្រក់ មិនអាចកែប្រែបាន ពួកគេព្យាយាមធ្វើអោយ ប្រជាពលរដ្ឋខ្មែរ និង អន្តរជាតិ ក្លាយទៅជាសត្វសេក និង សត្វសារិកា របស់ពួកគេអោយខាងតែបាន ។

**ខាងក្រោមនេះយើងសូមធ្វើការបំភ្លឺដល់លោក ហ៊ុន សែន ម្តងទៀតនូវអ្វីដែលលោកបានដឹង និង បានយល់ច្បាស់រួចមកហើយ ៗ**

នយោបាយនៃការគ្រប់គ្រងមនុស្សនៅក្នុងគណបក្សប្រជាជនកម្ពុជារបស់រដ្ឋាភិបាលយួនកម្មុយនិស្តក្រុងហាណូយ គឺគេបានចែក ជនកម្មុយនិស្តខ្មែរដែលជាខ្ញុំកញ្ជះដាច់ថ្លៃរបស់គេជា 02 ក្រុមធំៗ គឺមាន ៖

1- ក្រុមលោក ជា ស៊ីម

2- ក្រុមលោក ហ៊ុន សែន

ទាំងពីរក្រុមនេះ យួនក្រុងហាណូយ បានបែងចែកអំណាចការងារដាច់ដោយឡែកពីគ្នាក្រុមលោក ហ៊ុន សែន គឺជាអ្នកដឹកនាំកិច្ចការរដ្ឋ ចំណែកក្រុមលោក ជា ស៊ីម គឺជាអ្នកដឹកនាំកិច្ចការគណបក្សការបែងចែករបៀបនេះវាជា យុទ្ធវិធី មួយរបស់ក្រុងហាណូយ ដើម្បី ជាតុល្យភាពនៃ អំណាចរវាងក្រុមទាំងពីរ ឬ យើងចង់និយាយថាវា ( បំបែកបំបាក់ដើម្បីគ្រប់គ្រង) ហ្នឹងហ្មែង។

### ក្រុមលោក ជា ស៊ីម

ក្រុមលោក ជា ស៊ីម ជាក្រុមមនុស្សដែលមានវ័យចំណាស់ ជាក្រុមខ្មែរយៀកមិញ ក្រុមនេះមិនសូវមានអ្នកមានចំណេះប៉ុន្មានទេ ប៉ុន្តែជាក្រុមស្នូលរបស់គណបក្សប្រជាជនកម្ពុជា ដែលរដ្ឋាភិបាលយួនក្រុង ហាណូយ មានការទុកចិត្តជាទីបំផុត **គឺមានការទុកចិត្តច្រើនជាងក្រុម ហ៊ុន សែន** ។ ក្រុមនេះមានសិទ្ធិធ្វើជាប្រធានគណបក្សប្រជាជនកម្ពុជាជានិរន្តរ៍ មានសិទ្ធិដឹកនាំរដ្ឋសភា និង ព្រឹទ្ធសភាដែលគេតាំងឡើងមកសម្រាប់អោយលោក ហេង សំរិន អង្គុយលេងកូនអុក ដើម្បីកែអផ្សុក ជាមួយបុគ្គលមកពីគណបក្សផ្សេងៗមួយចំនួនដែលគេបញ្ឈរជើងពីកិច្ចរដ្ឋ និង កិច្ចការបក្ស ប៉ុន្តែក្រុមនេះមានសិទ្ធិទទួលខុសត្រូវ និង ចាត់ចែងលើកម្លាំងកងទ័ពជាតិទាំងមូល ។

ក្រុមលោក ជា ស៊ីម នេះជានិច្ចជាកាល រដ្ឋាភិបាលក្រុងហាណូយ គេមិនសូវប្រើអោយចេញមុខ ក្នុង

កិច្ចការរដ្ឋទេ ពីព្រោះយួនគេទុកមុខ របស់ក្រុមនេះ ដើម្បីប្រើប្រាស់នាពេលខាងមុខ ហើយតែងតែរក្សាមុខក្រុមនេះជានិច្ចកន្លងមក នៅពេលណាក្រុម ហ៊ុន សែន ចេញមុខធ្វើកិច្ចការអ្វីមួយ ដែលបណ្តាលអោយប៉ះពាល់ យ៉ាងធ្ងន់ធ្ងរដល់ ផលប្រយោជន៍ជាតិខ្មែរយើង ហើយបើក្រុមអ្នកប្រព្រឹត្តដោះស្រាយមិនបាន គឺពេលនោះយួនក្រុងហាណូយ គេនឹងប្រើប្រាស់ក្រុម ជា ស៊ីម នេះភ្លាម ដើម្បីធ្វើការទំនាក់ទំនង និង សម្របសម្រួលជាមួយ គូបដិបក្ខ ឬ ក្រុមគណបក្សប្រឆាំងផ្សេងៗ បានន័យថាអាក្រុមមួយធ្វើជាចោរ ឯអាក្រុមមួយទៀតធ្វើ POLICE ។ល។ និង ។ល។

កន្លងមកនេះយើងបានសង្កេតឃើញថាក្រុមអ្នកនយោបាយជាតិ និង អន្តរជាតិ រមែងតែងតែយល់ខុស និងយល់ច្រឡំយ៉ាងច្រើនទៅលើព្រឹត្តិកម្មរបស់គណបក្សប្រជាជនកម្ពុជាពួកគេតែងតែយល់និងគិតថាគណបក្សកុម្មុយនិស្តខ្មែរ ដែលមានយួនជាម្ចាស់មួយនេះ កំពុងតែមានការបែកបាក់ផ្ទៃក្នុង មានអ្នកខ្លះគិតថា គណបក្សដ៏មានឥទ្ធិពល លើឆាកនយោបាយខ្មែរមួយនេះ និង បែកជាពីរ បែកជាបី ទៅតាមអ្វីដែលគេគិត ប៉ុន្តជាការពិតអ្វីៗដែលអ្នកនៅខាងមើលឃើញនោះ គឺវាជា ឆាកល្ខោននយោបាយ ដែលយួនគេចាត់អោយពួកមេដឹកនាំដ៏ សែនល្ងង់ខ្លៅ នៃគណបក្សកុម្មុយនិស្តខ្មែរមួយនេះដើរតាមតែប៉ុណ្ណោះ ។

វាពិតជាមានការរកាំរកូស ឈ្លោះប្រកែកគ្នាមែន រវាងក្រុម ជា ស៊ីម និង ក្រុម ហ៊ុន សែន ដោយការបែងចែកអំណាច និង ផលប្រយោជន៍គ្នាមិនត្រូវ ប៉ុន្តែយើងសូមជម្រាបថា ពួកគេទាំងពីរក្រុមនេះ មិនអាចធ្វើអ្វីបានក្រៅតែពី ការរងចាំស្តាប់បញ្ជាផ្ទាល់ពីយួនក្រុងហាណូយតែប៉ុណ្ណោះ ពួកគេគ្មានផ្លូវនឹងជ្រើសរើសឡើយ ពីព្រោះទាំងពីរក្រុមនេះ ពិតជាបានយល់ និង បានមើលឃើញយ៉ាងច្បាស់នូវ កម្លាំងពិតរបស់យួន ដែល បានបង្កប់រួចមកហើយក្នុងប្រទេសកម្ពុជាយើង **គឺមានទាំងកម្លាំងមនុស្ស កម្លាំងសេដ្ឋកិច្ច និង កម្លាំងសស្ត្រាវុធ** ។ល។ និង ។ល។

គណបក្សប្រជាជនកម្ពុជាបានជ្រុលផុងខ្លួនជាយូរមកហើយ គឺតាំងតែពីលោក ចាន់ ស៊ី ស្លាប់មកម្ល៉េះ បន្ទាប់ពីរដ្ឋាភិបាលក្រុងហាណូយតែងតាំងលោក ហ៊ុន សែន អោយធ្វើជាអាយ៉ងជំនួសខ្មោចលោក ចាន់ ស៊ី រួចមកនិគមន៍ជនជាតិយួន ត្រូវបានគេ បញ្ជូន និង បញ្ចូល មកក្នុងប្រទេសកម្ពុជាយើង ជារៀងរហូតមកដល់សព្វថ្ងៃនេះ ចំណែក គណបក្សប្រជាជនកម្ពុជាវិញនោះ មិនអាចធ្វើការ ទប់ស្កាត់ ឬធ្វើអ្វីបានឡើយ ទោះបីជាពួកគេមើលឃើញយ៉ាងច្បាស់ថាគ្រោះមហន្តរាយដែលកំពុងឈានចូលមកដើម្បីយាយីប្រល័យជីវិតពួកគេជារៀងរាល់ថ្ងៃក៏ដោយចុះ ។

យើងក៏បានមើលឃើញថា នយោបាយមុខពីរ របស់យួនក្រុងហាណូយនេះបានទទួលលទ្ធផលល្អឥតខ្ចោះ ដូចជាកើតហេតុការណ៍ POLICE និង PM ឡោមព័ទ្ធផ្ទះ លោក ជា ស៊ីម នៅចំការមន កាលពីឆ្នាំ 2004 វាជាកលឧបាយមួយដែល ក្រុងហាណូយ ធ្វើបានល្អណាស់ នាពេលនោះទាំងភ្នែកជាតិ និង ភ្នែកអន្តរជាតិ គឺពិតជាមើលឃើញ និង យល់ឃើញដូចគ្នាថា ពួកគេ ជា ស៊ីម និង ហ៊ុន សែន កំពុងឈ្លោះគ្នាមែន បែកបាក់គ្នាមែន ប៉ុន្តែផ្ទុយទៅវិញគឺពេលនោះក្រុងហាណូយ គេមិនត្រូវការធ្វើអោយ គណបក្សប្រជាជនកម្ពុជា ជាប់ឈ្មោះក្នុងទំព័រ ប្រវត្តិសាស្ត្រថា ជាអ្នកធ្វើរដ្ឋប្រហាររដ្ឋធម្មនុញ្ញ ដើម្បីកាត់ដីព្រំដែនអោយយួន ។

នាពេលនោះរដ្ឋាភិបាលក្រុងហាណូយ គេមានបំណងចង់បាន ឡាយព្រះហស្តលេខា របស់ស្តេចកុម្មុយនិស្ត នរោត្តម សីហនុ លើរដ្ឋធម្មនុញ្ញដែលទើបកែឆ្នៃរួចថ្មីៗ នៅមុនពេល នរោត្តម សីហនុ លាចាកលោកយើងនេះទៅ ប៉ុន្តែពុំបានសម្រេច ព្រោះស្តេចកំហូចខិលខូចគ្មាននរណាប្រៀបមួយអង្គនេះដឹងខ្លួនទាន់ក្នុងនាមខ្លួនជាស្តេចកំពុងគ្រងរាជ្យនាពេលនោះបានធ្វើការបដិសេធជាបន្ទាន់ ពីព្រោះមិនត្រូវការ វិចស្តាយយកទៅជាមួយនៅពាក្យ ជេរ៍ប្រម៉ាត ប្រទេច បណ្តាសា ថាខ្លួនជាស្តេច ក្បត់ជាតិ ជាស្តេច លក់ជាតិ នៅពេលខ្លួនស្លាប់ហើយ ចុះទៅនៅឯឋាននរក អវជ័យ នោះ ។

ប៉ុន្តែនៅទីបំផុត កំហុស ទាំងអស់នាពេលនោះក៏នៅតែធ្លាក់ទៅលើពួក ស្តេច ពួករាជានិយម តែដដែលហ្នឹង គឺគណបក្ស (FUNCINPEC)ដោយពួកគេទាំង ស្តេច ទាំងរាស្ត្រ ទាំងខ្មែរ ទាំងយួន បានរុញ ច្រាន អោយលោក ញ៉ឹក ប៊ុន ឆៃ ជាអ្នកទទួលខុសត្រូវចំពោះមុខទំព័រប្រវត្តិសាស្ត្រមួយផ្ទាំងយ៉ាងធំ នាពេលនោះ។

ចំណែកលោក ជា ស៊ីម និង បរិវារ មួយចំនួន ក្រោយពីបានសម្តែងក្នុងឆាកល្ខោន ផ្ទះត្រូវបានគេ

ឡោមព័ទ្ធ រួចមក ក៏ធ្វើដំណើរចេញទៅលំហែរ ព្រះកាយ នៅប្រទេស ថៃឡង់ដ៍ ប៉ុន្តែត្រូវបានលោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី ជឿស្លុងក្នុងអារម្មណ៍ នឹកគិតថា ពួកគេពិតជាឈ្លោះគ្នាមែន ហើយដោយក្តីសង្ឃឹមយ៉ាងមុតមាំថាខ្លួននឹងអាច ញុះញង់ បញ្ចុះបញ្ចូល និង អូសទាញ ក្រុមលោក ជា ស៊ីម មកជាពួកដើម្បី កំចាត់កំចាយ ក្រុមលោក ហ៊ុន សែន ចេញអោយផុតពីអំណាច  ដោយពេញក្នុងក្តីសង្ឃឹមលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងបានខិតខំព្យាយាមស្វែងរកជួបជាមួយលោក ជា ស៊ីម ក្នុងប្រទេសថៃ  ប៉ុន្តែពុំបានសម្រេច  ព្រោះគ្មានការអនុញ្ញាតអោយជួបពីក្រុងហាណូយ  ។

## ក្រុមលោក ហ៊ុន សែន ៖

ក្រុមលោក ហ៊ុន សែននេះ មានសិទ្ធិត្រឹមតែធ្វើជាអនុប្រធានគណបក្សប្រជាជនកម្ពុជាជានិរន្តរ៍ ប៉ុន្តែមាន សិទ្ធិ ធ្វើជានាយករដ្ឋមន្ត្រី ដឹកនាំរដ្ឋាភិបាលជារឿយៗក្រុមនេះជាក្រុម អ្នកលេង ក្រុមដៃដល់ ក្រុមឧក្រិដ្ឋជន ក្រុមនេះមានមនុស្សវ័យក្មេងៗ និងមានចំណេះខ្ពស់ៗជាច្រើនទើបមិនសូវមានការទុកចិត្តពីសត្រូវយួនក្រុងហាណូយ ហើយក្រុមនេះមាន ភារកិច្ច និង កាតព្វកិច្ច រកផលប្រយោជន៍មកបំរើ អោយគណបក្ស ប្រជាជនកម្ពុជា ប៉ុន្តែក្រុមនេះមានសិទ្ធិទទួល ខុសត្រូវលើកងកម្លាំងនគរបាលជាតិទាំងមូល ។

### ខាងក្រោមនេះយើងសូមធ្វើការអធិប្បាយបញ្ជាក់នៅព្រឹត្តិកម្ម ដ៏ខ្មៅក្រខ្វក់របស់ក្រុមលោកហ៊ុន សែនក្នុងនាវកិច្ចរកប្រយោជន៍មកបំរើ គណបក្សប្រជាជនកម្ពុជា ទាំងអតីតកាល និង បច្ចុប្បន្នកាល ។

ទោះជាភារកិច្ច ឬ កាតព្វកិច្ច ដែលរដ្ឋាភិបាលយួនក្រុងហាណូយបានកំណត់អោយក្រុមហ៊ុន សែន ត្រូវតែអនុវត្តដោយខានមិនបាន យើងសូមអធិប្បាយត្រួសៗដូចតទៅនេះ ។

មុនការបោះឆ្នោតជាសាកលនាឆ្នាំ1993 រដ្ឋាភិបាលនាពេលនោះគឺជារដ្ឋាភិបាល រដ្ឋកម្ពុជា ដែលដឹកនាំដោយ  គណបក្សប្រជាជនបដិវត្តកម្ពុជា  ដែលមានលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រី និង ក្រោយការបោះឆ្នោត ឆ្នាំ1993 រហូតមកដល់សព្វថ្ងៃនេះ ប្រទេសកម្ពុជាយើងដឹកនាំផ្ទាល់ដោយ គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សចាញ់ឆ្នោត មិនមែនគណបក្ស(FUNCINPEC)ដែលដឹកនាំផ្ទាល់ដោយស្តេចកម្ពុយនិស្ត នរាត្តម សីហានុ ទេ

នាពេលនោះគណបក្សប្រជាជនកម្ពុជាដែលមានរូបលោក  ហ៊ុន សែន ជាអនុប្រធានបានបន្តធ្វើអាជីវកម្ម ជំនួញគ្រឿងញៀន យ៉ាងសកម្មដោយមានលោក ថេង ប៊ុនម៉ា ខ្មែរសញ្ជាតិថៃជាអ្នកចេញមុខធ្វើជំនួញផ្ទាល់ ដើម្បីយកប្រាក់មកចិញ្ចឹមគណបក្ស  ប៉ុន្តែនៅឆ្នាំ1997  លោក ថេង ប៊ុនម៉ា  ត្រូវបានគេដឹង ឮ ជាសាធារណថាជាប់ពាក់ព័ន្ធ នឹង ការធ្វើជំនួញ គ្រឿងញៀនរវាងប្រទេស  ទើបតម្រូវអោយរដ្ឋាភិបាលថៃឡង់ដ៍ ដែលដឹកនាំដោយលោក ឆៅលិត យ៉ុងថៃយុត នាពេលនោះដកហូតយកសញ្ជាតិថៃពីលោក ថេង ប៊ុនម៉ា វិញ  ។

ចំណែកគណបក្សប្រជាជនកម្ពុជាវិញ ដើម្បី បិទបាំងខ្លួន និង ដើម្បី ទម្លាក់កំហុស ទាំងអស់ទៅលើ លោក ថេង ប៊ុនម៉ា ពួកគេក៏បញ្ឈប់លោក ថេង ប៊ុនម៉ា ភ្លាមនាពេលនោះ រួចហើយពួកគេក៏បង្កើត ក្រុមឧក្រិដ្ឋជនថ្មីមួយមកជំនួសវិញភ្លាមដែរ ដោយអោយឈ្មោះថា(Special Organization of Youths)(SOY)។

### ក្រុមឧក្រិដ្ឋជនថ្មីនេះជា អង្គការសម្ងាត់មួយ របស់គណបក្សប្រជាជនកម្ពុជាដោយមានកាតព្វកិច្ចសំខាន់ៗដូចតទៅនេះ ៖

1-ធ្វើជំនួញ គ្រឿងញៀន ទាំងក្នុងប្រទេស និង ក្រៅប្រទេស ។

2- ប្រព្រឹត្ត បទឧក្រិដ្ឋផ្សេងៗ ទាំងក្នុងប្រទេស និង ក្រៅប្រទេស ។

3- ប្រព្រឹត្តអំពើ ចារកម្ម ទាំងក្នុងប្រទេស និង ក្រៅប្រទេស ។

4- ធ្វើជំនួញ ងងឹត ផ្សេងៗជាមួយ ពួកជនឧក្រិដ្ឋរវាងប្រទេស ដូចជា ការជួញដូរគ្រឿងសស្ត្រាវុធ ការជួញដូរមនុស្ស ការជួញដូរសម្បត្តធម្មជាតិ និង ការជួញដូរដីធ្លី ។ល។ និង ។ល។

រឿងរ៉ាវទាំងអស់ដូចដែលបាន អធិប្បាយមកខាងលើនេះបើយើងមើលត្រួសៗ ឃើញថាជារឿងធម្មតារបស់ពួកជនឧក្រិដ្ឋ ប៉ុន្តែបើយើងមើលអោយចំទៅលើគណបក្សប្រជាជនកម្ពុជា និង លោក ហ៊ុន  សែន ដែល

ជា ប្រមុខរដ្ឋាភិបាលកម្ពុជាទើបឃើញថាមិនធម្មតា ។

យើងសូមអោយឈ្មោះរដ្ឋាភិបាលដែលដឹកនាំដោយលោក ហ៊ុន សែន នាបច្ចុប្បន្នកាលនេះថាជារដ្ឋាភិបាល ម៉ាហ្វីយ៉ា (MAFIA) ។

ទាំងអស់នេះគឺជា អំពើ និង ការប្រព្រឹត្ត ដែលវាបានក្លាយទៅជា ទម្លាប់ របស់ជនកម្មុយនិស្ត ផ្តាច់ការ មិនថាឡើយជនទាំងនោះនៅកន្លែងណា និង មានមុខតំណែងជាអ្វី គេតែងតែធ្វើអោយបាន និង យកមកអោយបាននៅអ្វីដែលគេត្រូវការ ដោយមិនបានគិតដល់នូវ ទង្វើ សកម្មភាព និង មធ្យោបាយឡើយ វាជាអំពើឧក្រិដ្ឋ និង អំពើបាបយ៉ាងធ្ងន់ធ្ងរ ដែលគណបក្សប្រជាជនកម្ពុជា និង ក្រុមលោក ហ៊ុន សែន បានធ្វើ កំពុងនិងធ្វើ និង បន្តធ្វើទៅអនាគត់ ។

ខាងក្រោមនេះគឺជាការដាស់តឿនក្រើនរំលឹកដល់ក្រុមលោក ហ៊ុន សែន អំពីការវិវឌ្ឍន៏នៃដំណើរ នយោបាយរបស់ក្រុមខ្លួន ដែលរដ្ឋាភិបាលយួនក្រុងហាណូយ កំពុងធ្វើការពិនិត្យ តាមដាន យ៉ាងសកម្ម និង យកចិត្តទុកដាក់ជាទីបំផុត ។

រឿងនេះយើងសូមធ្វើការបែងចែកជា 02 តំណាក់ការណ៍ ៖

តំណាក់ការណ៍ទី01 ៖ គឺក្រោយថ្ងៃ រដ្ឋប្រហារ 5-6 ខែកក្កដា ឆ្នាំ1997 ។

តំណាក់ការណ៍ទី02 ៖ គឺក្រោយថ្ងៃ ស្តេចកម្មុយនិស្ត នរោត្តម សីហនុ ស្លាប់ ។

ក្រោយថ្ងៃរដ្ឋប្រហារ 5-6 ខែកក្កដា1997៖ជាការពិតណាស់ថាយួនក្រុងហាណូយគេ មិនត្រូវការ អោយ ហ៊ុន សែន ធ្វើរដ្ឋប្រហារបណ្តេញ នរោត្តម រណឫទ្ធិ ចេញពីតំណែងនោះទេ ព្រោះគេដឹងថាវាគ្មាន ចំណេញអ្វី ទាល់តែសោះដល់ នយោបាយ របស់ពួកគេ គឺមានតែខាត ប៉ុន្តែគេចាំបាច់ត្រូវតែអនុញ្ញាតអោយធ្វើ ហើយជួយ អន្តរាគមន៍ថែមទៀត ពីព្រោះ រដ្ឋាភិបាលក្រុងហាណូយគេបានមើលឃើញយ៉ាងច្បាស់ថាក្រុម ហ៊ុន សែន កំពុងចាញ់ប្រៀប (FUNCINPEC) យ៉ាងខ្លាំង ទាំងផ្នែក នយោបាយ ផ្នែកសេដ្ឋកិច្ច ផ្នែកកម្លាំង ផ្នែកប្រជាប្រិយភាព និង ជាពិសេសគឺ មិនអាច ទប់ស្កាត់បាន នូវកម្លាំង សម្ងាត់ របស់(FUNCINPEC)ដែលដឹកនាំផ្ទាល់ដោយលោក ហូ សុខ ។

ទាំង 05 ផ្នែកខាងលើនេះគឺជា មូលហេតុដ៏សំខាន់ ដែលបណ្តាលអោយគណបក្សប្រជាជនកម្ពុជា និង យួនរួមដៃគ្នាធ្វើរដ្ឋប្រហារ ប្លន់អំណាចពីប្រជាពលរដ្ឋនាថ្ងៃទី 5-6 កក្កដា 1997 សួរថា តើមានអ្វីគួរអោយយើងនិយាយ និង លើកកកាយឬទេ ? គឺមានពិតប្រាកដ ៖

1-ផ្នែកនយោបាយ ៖ (FUNCINPEC)ជាក្រុមរាជានិយម( ស៊ីន សាន )ជាក្រុមសេរីនិយម ដែលមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ជាតិ និង អន្តរជាតិ ហើយកំពុងមានការរីកចំរើនលូតលាស់ដែលគួរជាទីពេញនិយម ។

2-ផ្នែកសេដ្ឋកិច្ច ៖ (ហ៊្វុន ស៊ីន ប៊ិច)(ស៊ីន សាន) បានទទួលការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ នាយទុនធំៗទាំងនៅក្នុងប្រទេស និង ក្រៅប្រទេស រួមទាំងអង្គការរូបីយប័ណ្ណអន្តរជាតិផ្សេងៗ របស់ពិភពលោក ។

3-ផ្នែកកម្លាំងប្រដាប់អាវុធ ៖ (ហ៊្វុន ស៊ីន ប៊ិច)(ស៊ីន សាន)(ខ្មែរក្រហម) បានចាប់ដៃគ្នាជាកម្លាំងជាតិមួយឆ្ពោះទៅរកមធ្យោបាយការពាររដ្ឋាភិបាលថ្មីមួយនៅក្រោយការបោះឆ្នោតឆ្នាំ1998 ដែលយើងជឿថាគណបក្ស(FUNCINPEC)ជាអ្នកឈ្នះ ប៉ុន្តែយើងមើលឃើញយ៉ាងច្បាស់ថាគណបក្សប្រជាជន និង ហ៊ុន សែន ពិតជាមិនព្រមចាញ់ដូចឆ្នាំ93។

4-ផ្នែកប្រជាប្រិយភាព ៖ប្រជាពលរដ្ឋខ្មែរយើងស្ទើតែ100%ស្រឡាញ់របបសេរីប្រជាធិបតេយ្យស្អប់ណាស់របបកម្មុយនិស្តមហាផ្តាច់ការដែលជាកាកសំណល់ពីរបបប្រល័យពូជសាសន៍(ប៉ុល ពត)។

5-ផ្នែកកម្លាំងសម្ងាត់ ៖ (ហ៊្វុន ស៊ីន ប៊ិច) (ស៊ីន សាន) (ខ្មែរក្រហម) កម្លាំងនេះគឺប្រៀបបីដូចជា មេភ្លើង ជាបីសាច ដែលតាមលង តាមបន្លាច តាមបំភិត តាមបំភ័យ ពួកកម្មុយនិស្តដែលជា ជនឧក្រិដ្ឋ មិនអាច ដេកបាន ស៊ីបាន និង អង្គុយបានស្រួលម្តងណាឡើយនាពេលនោះ ហើយយើងជឿជាក់ថាខ្មែរយើងគ្រប់ៗគ្នាពិតជា បានដឹង បានឮ រួចមកហើយ អំពីរឿងរ៉ាវទាំងអស់ហ្នឹង ។

លោក ហូ សុខ ដែលជា មេបញ្ជាការ ផ្ទាល់លើកម្លាំងសម្ងាត់រួមនាពេលនោះ បានធ្វើការព្យាយាមយ៉ាងខ្លាំងដើម្បី ជីកឫស រំលើងគល់ របស់គណបក្សប្រជាជនកម្ពុជា និង ក្រុមលោក ហ៊ុន សែន ដែលកំពុងប្រព្រឹត្ត

បទឧក្រិដ្ឋៗជាច្រើនដូចជា ជួញដូរគ្រឿងញៀន ជួញដូរលុយក្រខ្វក់ ជួញដូរមនុស្ស បង្កប់ឧក្រិដ្ឋជនសំខាន់ៗដែលបានរត់គេចខ្លួនពីប្រទេសផ្សេងៗមកក្នុងប្រទេសកម្ពុជាយើង បង្កប់កម្លាំងទ័ពយួន កម្លាំងចារកម្មយួន និង និគមន៍ជនជាតិយួន ។ល។ និង ។ល។

ការប្លន់អំណាចដោយកម្លាំងទ័ពរួម ខ្មែរ យួន បានទទួលជ័យជំនះជាស្ថាពរប៉ុន្តែជាអកុសល ធំណាស់សម្រាប់ ក្រុមលោក ហ៊ុន សែន គឺត្រូវបាន ជាតិ និង អន្តរជាតិ ថ្កោលទោសយ៉ាងខ្លាំងក្លា ហើយថែមទាំងប្រកាស់ ផ្តាច់ជំនួយគ្រប់បែបយ៉ាងដល់ប្រទេសកម្ពុជា ជាហេតុធ្វើអោយរដ្ឋាភិបាល អ៊ឹង ហ៊្វត ដែលដឹកនាំផ្ទាល់ដោយ ហ៊ុន សែន មានការលំបាកយ៉ាងខ្លាំង រកកល់នឹងស្លាប់ ម្តងៗនាពេលនោះ ។

ប៉ុន្តែជា មហាគ្រោះថ្នាក់ថ្មីមួយទៀតសម្រាប់ជាតិ និង មាតុភូមិ ខ្មែរយើងដែលបង្កឡើង ដោយ ស្តេចកម្មុយនិស្ត នរោត្តម សីហានុ និង ម៉ូនិក សីហានុ រហូតមកដល់សព្វថ្ងៃនេះ ដោយពួកគេមើលឃើញចំណុចខ្សោយរបស់គណបក្ស ប្រជាជនកម្ពុជា និង ក្រុមលោក ហ៊ុន សែន ជាហេតុបណ្តាលអោយគំនិតដ៏ល្មោភ និង មហាចង្រៃឧបទ្រពរបស់ នរោត្តម សីហានុ ដែលមានបំណងប្រាថ្នាយ៉ាងខ្លាំងក្លាដើម្បីចិញ្ចឹមអោយបាន នូវរបបកម្មុយនិស្តជានិរន្តរ៍ក្នុងប្រទេសកម្ពុជាយើង រួមផ្សំនឹងមហាអំណាចចិនកម្មុនិស្តក្រុងប៉េកាំងមើលឃើញប្រយោជន៍ដ៏មហាសាលសម្រាប់ប្រទេសជាតិរបស់គេគឺ ៖

1- ទទួលយកក្រុមលោក ហ៊ុន សែន មកធ្វើជាអាយ៉ងថ្មីរបស់ខ្លួនជំនួសអោយ ក្រុមខ្មែរក្រហមនិយមចិន ប៉ុល ពត ។

2- ដើម្បីអោយក្រុម ហ៊ុន សែន ចិញ្ចឹម បីបាច់រក្សា និង ការពារ អោយបាននូវ កម្លាំងកងទ័ពរបស់ខ្មែរ ក្រហម ប៉ុល ពត អោយនៅគង់វង្សស្ថិតស្ថេរចិរកាលទៅអនាគត់ ។

3- រដ្ឋាភិបាលកម្មុយនិស្តក្រុងប៉េកាំងបានបញ្ចូល និង បញ្ជូន មនុស្សរបស់គេរាប់ម៉ឺននាក់អោយចូល មកស្នាក់នៅក្នុងប្រទេសកម្ពុជាយើង ដើម្បី មកធ្វើជាទីប្រឹក្សា ជាអ្នកវិនិយោគទន់ ។ល។ និង ។ល។

4- រដ្ឋាភិបាលកម្មុយនិស្ត ក្រុងប៉េកាំងត្រូវការរក្សា ការពារ និង ពង្រីកឥទ្ធិពលរបស់ខ្លួននៅលើថ្វីបអាស៊ីអាគ្នេយ៍យើងនេះ ។

5-រដ្ឋាភិបាលកម្មុយនិស្ត ក្រុងប៉េកាំង ត្រូវការជាចាំបាច់អោយមាន ផែរកប៉ាល់ចម្បាំង និង វាលយន្តហោះចម្បាំង នៅក្នុងប្រទេសកម្ពុជាយើងនាពេលអនាគត់ដ៏ខ្លីខាងមុខនេះ ។

6- រដ្ឋាភិបាលចិនកម្មុយនិស្តក្រុងប៉េកាំង និង ស្តេចកម្មុយនិស្ត នរោត្តម សីហាន មានបំណងប្រាថ្នាយ៉ាងខ្លាំងក្លាក្នុងការ ទប់ស្កាត់ និង ការពារ អោយបានជាស្ថាពរនៅការបង្កើតឡើងវិញជាថ្មីនូវ របបសាធារណរដ្ឋសេរី និង របបប្រជាធិបតេយ្យសេរីពិត នៅក្នុងប្រទេសកម្ពុជានាពេលអនាគត់ ។

ហេតុផលធំៗទាំង 06 ប្រការខាងលើនេះហើយដែលបណ្តាលអោយរដ្ឋាភិបាលកម្មុយនិស្ត ក្រុងប៉េ កាំង ព្រមទទួលយកក្រុម ហ៊ុន សែន មកធ្វើជាអាយ៉ងថ្មី ដោយក្តីសប្បាយរីករាយជាទីបំផុត ហើយភ្លាមៗនោះដែររដ្ឋាភិបាលចិនក្រុងប៉េកាំង ក៏បានផ្តល់រង្វាន់ជាគ្រឿងសស្ត្រាវុធដល់ ហ៊ុន សែន ដើម្បីយកមក ច្បាំងជាមួយកម្លាំងទ័ពរបស់ (ហ៊្វុន ស៊ិនប៉ិក) (ស៊ឺន សាន) និង(ខ្មែរក្រហម) ដែលមិនព្រមចុះចាញ់ ហើយបោះទីតាំងធំនៅព្រុំប្រទល់ ដែនខ្មែរ - ថៃ ដែលជាមូលដ្ឋានទ័ពចាស់(អូរស្មាច់) និង (អន្លង់វែង) ដោយមានលោក ញ៉ឹក ប៊ុន ឆៃ លោក ខាន់សាវឿន និង តាម៉ុក ជាមេបញ្ជាការផ្ទាល់ ។

មិនត្រឹមតែប៉ុណ្ណឹងទេ ម៉ូនិក សីហានុ បានឆក់យកឱកាសដ៏កម្ររកបាននេះ ទៅរួមគំនិតជាមួយ ហ៊ុន សែន ជាមួយ រដ្ឋាភិបាលកម្មុយនិស្តយួនក្រុងហាណូយ និង រដ្ឋាភិបាលចិនកម្មុយនិស្តក្រុងប៉េកាំងបង្ខំ អោយ នរោត្តម សីហានុ ដាក់រាជ្យសម្បត្តិ ដើម្បីអោយ នរោត្តម សីហាមុនី ឡើងគ្រងរាជបល្ល័ង្កជំនួសវិញ ។

បើតាមចារឹកដ៏សែនកំហូចខឹលខូចគ្មាននរណាបៀបរបស់ ស្តេចកម្មុយនិស្ត នរោត្តម សីហានុ គឺពិតជា មិនព្រមឡើយ ប៉ុន្តែដោយហេតុថា ៖

1- រដ្ឋាភិបាលចិនកម្មុយនិស្តក្រុងប៉េកាំងបង្ខិតបង្ខំ ។

2- ម៉ូនិក សីហានុ បង្ខិតបង្ខំ ។

3- អាយ៉ងខ្ញុំកញ្ជះចិន កញ្ជះយួន គំរាមផ្តួររបប ។

4- ដើម្បីរក្សា និង ការពារ អោយបាននូវរបបរាជានិយមក្នុងប្រទេសកម្ពុជាយើង ។

*5- ដើម្បីកុំអោយយួនក្រុងហាណូយកើតក្តីមិនទុកចិត្តលើក្រុមលោក ហ៊ុន សែន ។*

*6-ដើម្បីរក្សា និង ការពារ អោយបាននូវផលប្រយោជន៍មហាសាលរបស់ចិនកម្មុយនិស្តក្រុងប៉េកាំង*

*រឿងរ៉ាវទាំងអស់ដែលយើងបានអធិប្បាយបកស្រាយមកខាងលើនេះវាគឺជាផលប្រយោជន៍រួមគ្នារវាង ម៉ូនិក សីហនុ - ក្រុមលោក ហ៊ុន សែន និង មហាអំណាចកម្មុយនិស្តចិនក្រុងប៉េកាំង ។*

**ការរួមដៃគ្នារវាង មហាអំណាចកម្មុយនិស្តចិនក្រុងប៉េកាំង - ម៉ូនិក សីហនុ និង ក្រុមលោក ហ៊ុន សែន សួរថាតើ យួនកម្មុយនិស្តក្រុងហាណូយ ទទួលបានផលប្រយោជន៍អ្វីខ្លះ ?ហើយតើគេគិតដូចម្តេចខ្លះ ចំពោះវាសនា និង អនាគត់ របស់ក្រុមលោក ហ៊ុន សែន ?**

***1-***ទម្លាក់ស្តេចកម្មុយនិស្ត នរោត្តម សីហនុ *ចេញពីរាជបល្ល័ង្គ* គឺប្រៀបបាននឹងកំចាត់ ស្តេចក្បត់ជាតិខ្លួនឯង មួយនេះ *ចេញពីលើឆាកនយោបាយ*ដោយងាយស្រួលជាទីបំផុត ដោយមិនចាំបាច់ប្រើអំពើហឹង្សា ។*

***2-*** *កាត់យកទឹក- ដី ព្រំដែនខ្មែរដោយត្រង់ៗ ។*

***3-*** *បង្ហូរបញ្ចូលនិគមន៍ជនជាតិយួនបន្ថែមរាប់លាននាក់មកក្នុងកម្ពុជារហូតដល់សព្វថ្ងៃនេះ ។*

***4-*** *រក្សា និង ការពារ បាននូវរដ្ឋាភិបាលអាយ៉ងខ្ញុំកញ្ជះរបស់គេរហូតមកដល់ពេលនេះ។*

**ប៉ុន្តែមានចំណុចមួយដែលធ្វើអោយរដ្ឋាភិបាលយួនកម្មុយនិស្តក្រុងហាណូយមានសេចក្តីព្រួយបារម្ភណ ហើយកំពុងតែបានក្លាយទៅជាការពិតនោះគឺ ៖**

*គឺក្រុមលោក ហ៊ុន សែន បានក្លាយខ្លួនទៅជាអាយ៉ងខ្ញុំកញ្ជះចិនមួយទៀតដោយបរិយ៉ាយ តាំងតែពីពេលនោះមក ជាហេតុបណ្តាលអោយរដ្ឋាភិបាលយួនហាណូយ ដកសេចក្តីទុកចិត្តស្ទើតែទាំងអស់ពីក្រុម ហ៊ុន សែន ពីព្រោះយួនគេជឿថាក្រុម ហ៊ុន សែន នេះកំពុងតែដើរតាម (គន្លងខ្មោច ប៉ុល ពត )។*

*តាំងតែពីពេលនោះមករដ្ឋាភិបាលយួនក្រុងហាណូយ និង ក្រុមលោក ហ៊ុន សែន មិនដែលមើលមុខគ្នាត្រង់ ៗទេ ដោយក្រុមលោក ហ៊ុន សែន មានសំអាងទាំងស្រុងទៅលើ ថៅហ្វាយនាយថ្មីដែលជា មហាអំណាចមួយ នៅលើលោកយើងនេះដែលកំពុងឈរធ្វើជាបង្អែក និង ជាខ្នងថ្មីរបស់ខ្លួន ពួកគេក៏តាំងខ្លួនជា អមិត្ត ភ្លាមៗដែរជាមួយថៅហ្វាយនាយចាស់ ក្រោយពីការកើតមាននូវបញ្ហាព្រំដែន។*

*ចំណែករដ្ឋាភិបាលយួនកម្មុយនិស្តក្រុងហាណូយ ក៏មិនបានបន្ធូរបន្ថយអោយក្រុមលោក ហ៊ុន សែន ដកដង្ហើមបានស្រួលម្តងណាឡើយចាប់តាំងតែពីគេដឹងច្បាស់ថា ពួកគេមិនអាចរារាំង និង ទប់ស្កាត់ មិនអោយក្រុម ហ៊ុន សែន បែកចេញពីការគ្រប់គ្រង ( នឹមដែក ឬ នឹមអាណានិគមន៍) របស់ខ្លួនបានមក រដ្ឋាភិបាលយួនក្រុងហាណូយ ក៏បានចាប់ផ្តើមធ្វើការកៀបសង្កត់ទៅលើក្រុមលោក ហ៊ុន សែន ភ្លាមៗនោះដែរ ដូចដែលយើងបានធ្វើការអធិប្បាយរៀបរាប់រួចមកហើយនៅខាងលើនេះ ។*

*ដោយអំណាចរបស់គណបក្សប្រជាជនកម្ពុជា និង ដោយអំណាចរបស់រដ្ឋសភាខ្មែរយើងបានស្ថិតនៅ ក្នុងដៃរបស់ ក្រុម លោក ជា ស៊ីម នោះគឺវាប្រៀបបាននឹងអំណាចទាំងអស់របស់ជាតិខ្មែរយើងវាបានធ្លាក់ទៅលើកណ្តាប់ដៃរបស់យួនក្រុងហាណូយ ទាំងស្រុងរួចទៅហើយ ដូច្នេះហើយទើបមានហេតុការណ៍ សំខាន់ជាច្រើនកើតមានឡើងកន្លងមក ប៉ុន្តែក្រុមលោក ហ៊ុន សែន ដែលជារដ្ឋាភិបាលមិនអាចប្រកែក ឬ រារាំង ឬ ទប់ស្កាត់អ្វីបានក្រៅតែពី ធ្វើតាមការបង្គាប់បញ្ជារបស់ក្រុងហាណូយរហូតមកដល់សព្វថ្ងៃនេះ ។*

***មានកិច្ចការមួយដែលសំខាន់ជាទីបំផុតសម្រាប់ក្រុមលោក ហ៊ុន សែន នោះគឺ ការស្នងតំណែងនាយករដ្ឋមន្ត្រី នៃប្រទេសកម្ពុជានពេលអនាគត់ ដែលជាតំណែងប្រចាំរបស់ក្រុមលោក ហ៊ុន សែន ប៉ុន្តែវាអាស្រ័យ ទៅលើគណបក្សប្រជាជនកម្ពុជា និង រដ្ឋាទិបាលយួនកម្មុយនិស្តក្រុងហាណូយជាអ្នកសម្រេច និង អនុម័ត្ត ៗ***

*ជាការពិតគឺ ក្រុមលោក ហ៊ុន សែន មានការធុញទ្រាន់ និង រកាំរកូស ជាមួយរដ្ឋាភិបាលយួនកម្មុយនិស្តក្រុងហាណូយ ចាប់តាំងពីឆ្នាំ 1997 មកម្ល៉េះ ប៉ុន្តែមកខ្លាំងភ្លាបំផុតនោះគឺបញ្ហាកាត់ព្រំដែន រដ្ឋាភិបាល*

យួនក្រុងហាណូយ បានលើកយកលោក កែ គឹម យ៉ាន ដែលមានតំណែងជា អគ្គមេបញ្ជាការកងទ័ពជាតិ នាពេលនោះ មកគាំពាមថានឹងអោយ លោក កែ គឹមយ៉ាន ធ្វើជានាយករដ្ឋមន្ត្រី ជំនួសលោក ហ៊ុន សែន នៅឆ្នាំ1998 បើលោក ហ៊ុន សែន មិនព្រម កាត់ព្រំដែន និង បើកចំហរ អោយនិគមន៍ជនជាតិយួនចូលមករស់នៅក្នុងប្រទេសកម្ពុជាដោយសេរីទេនោះ ។

ដោយសំអាងទៅលើ ចៅហ្វាយនាយថ្មី ដែលជាមហាអំណាចមួយនៅលើពិភព លោកយើងនេះនៅពី ក្រោយខ្នង នៅត្រង់ចំណុចដ៏សែនក្តៅនេះ យើងបានឃើញហើយថាវាសនា និង អនាគត់ របស់ លោក កែ គឹម យ៉ាន ទៅជាយ៉ាងណា គឺ ហ៊ុន សែន ដកក្រវាត់ចោលដូចដកកូនស្មៅអញ្ចឹង ហើយតាំងពីពេលនោះមកក្រុម លោក ជា ស៊ីម ក៏ត្រូវបានក្រុម លោក ហ៊ុន សែន បំផ្លិច បំផ្លាញ បណ្តើរៗ រហូតមកដល់សព្វថ្ងៃនេះ ដោយគេបាន បញ្ចូលមនុស្សរបស់ខ្លួនគេមកជំនួសវិញ ។

**ចំណែកក្រុមលោក ជា ស៊ីម វិញតើពួកគេបានធ្វើអ្វីខ្លះ ដើម្បីតបតទៅនឹងក្រុមលោក ហ៊ុន សែន ?**

គឺមានដែរ តែមិនមានប្រសិទ្ធិភាពប៉ុន្មានទេ ព្រោះត្រូវបានទប់ស្កាត់ដោយក្រុមលោក ហ៊ុន សែន ស្ទើតែទាំងអស់ គឺធ្វើបានតែមួយដែលជាថ្នូរ និង លោក កែ គឹម យ៉ាន គឺលោក ហុក ឡុង ឌី ហ្នឹងហ្អែង ។

## ក្រោយថ្ងៃស្តេចកម្មុយនិស្ត នរោត្តម សីហនុ ស្លាប់ ៖

ចាប់តាំងពីឆ្នាំ 1997 រហូតមកដល់ថ្ងៃដែលស្តេចកម្មុយនិស្ត នរោត្តម សីហនុ ស្លាប់គឺមានរយះពេល 15 ឆ្នាំ ក្រុមលោក ហ៊ុន សែន បានព្យាយាមកំចាត់មនុស្សសំខាន់ៗក្នុងគណបក្សប្រជាជនកម្ពុជា ដែលជាក្រុម លោក ជា ស៊ីម និង ក្រុមលោក ហេង សំរិន ដូចដែលយើង បានដឹង បានឮ ជាញឹកញប់ កន្លងមក និងកំពុងបន្ត ធ្វើ ក្នុងរូបភាព កំចាត់អំពើពុករលួយ កំចាត់ពួកឈ្មួញជួញដូរគ្រឿងញៀន និង កំចាត់ពួកឧក្រិដ្ឋជន ។ល។ និង ។ល។

សកម្មភាពរបស់ក្រុមលោក ហ៊ុន សែន ខាងលើនេះធ្វើអោយក្រុមលោក ជា ស៊ីម និង រដ្ឋាភិបាល ក្រុងហាណូយ កើតមានក្តីព្រួយបារម្ភយ៉ាងខ្លាំង ប៉ុន្តែមិនអាចធ្វើការទប់ស្កាត់អ្វីបាន ពីព្រោះពួក ហ៊ុន សែន បាន សំអាងទៅលើការអនុវត្តន៍តាមច្បាប់ ។

មកទល់នឹងពេលនេះពេលដែល នរោត្តម សីហនុ ស្លាប់យួនក្រុងហាណូយ និង ក្រុមលោក ជាស៊ីម រិតតែមានសេចក្តីបារម្ភកាន់តែខ្លាំងឡើងថែមទៀត ព្រោះពួកគេមើលឃើញថា រដ្ឋាភិបាលចិនក្រុង ប៉េកាំង និង ធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយក្រុមលោក ហ៊ុន សែន ដោយមិនចាំបាច់មានអ្នករត់ការឬ(ឈ្មួញកណ្តាល) ដូចជា នរោត្តម សីហនុ ដូចពេលមុនៗនោះទៀតឡើយ ។

នៅត្រង់ចំណុចនេះ ធ្វើអោយរដ្ឋាភិបាលក្រុងហាណូយ មានជំនឿយ៉ាងមុតមាំថា ក្រុមលោក ហ៊ុន សែន កំពុងតែដើរតាម( គន្លងចាស់ ) របស់ក្រុមខ្មែរក្រហមនិយមចិន ប៉ុល ពត ចំណែកក្រុមលោក ហ៊ុន សែន វិញក៏បានយល់យ៉ាងច្បាស់ណាស់ដែរនូវ គំនិតដ៏សែនពិះពុល របស់យួន ហាណូយជាយូរមកហើយដែរទើបពួកគេព្យាយាម **ប្រមែ ប្រមូល ពង្រឹង និង ពង្រីក កម្លាំងរបស់ខ្លួនយ៉ាងសកម្ម ដោយមិនសូវរើរវល់នឹង រដ្ឋាភិបាលក្រុង ហាណូយប៉ុន្មានទេសព្វថ្ងៃនេះ ។**

នាបច្ចុប្បន្នកាលក្តី ឬ អនាគត់កាលក្តី យើងមើលឃើញថាក្រុមលោក ជា ស៊ីម និង យួន គេនៅមានប្រៀបច្រើនណាស់ទៅលើក្រុមលោក ហ៊ុន សែន ពីព្រោះប្រទេសកម្ពុជាយើងសព្វថ្ងៃ ប្រើប្រាស់ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំប្រទេស ហើយក្រុម ហ៊ុន សែន ក៏ត្រូវតែដើរតាមរបៀបរបបនេះដែរ ។

ទាំងជាតិទាំងអន្តរជាតិតែងតែបានឮរួចមកហើយនូវពាក្យ(អំនួតក្តែងៗ)របស់លោក ហ៊ុន សែន ដែលថា ខ្លួនបានធ្វើជា នាយករដ្ឋមន្ត្រីនៃ ប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃនេះ គឺប្រជាជនជាអ្នកបោះឆ្នោតអោយ ដូច្នេះ យើងគ្រប់ៗគ្នាពិតជាបានដឹងរួចមកហើយថា សន្លឹកឆ្នោតដែលគណបក្សប្រជាជន កម្ពុជាទទួលបានកន្លងមក នេះគឺ70% ជារបស់ជនជាតិយួន សួរថាបើយួនគេទុកក្រុម ហ៊ុន សែន ជាសត្រូវ ហើយបើយួនគេគិតថាក្រុមលោក ហ៊ុន សែន អស់មានប្រយោជន៍សម្រាប់ពួកគេហើយនោះ តើមានហេតុការណ៍ក្តៅគគុកយ៉ាងណាខ្លះ នឹង កើតមាន

ឡើងចំពោះក្រុមលោក ហ៊ុន សែន ? ។

ចំពោះរឿងរ៉ាវទាំងអស់នេះគឺក្រុមលោក ហ៊ុន សែន បានត្រៀមខ្លួនរួចជាស្រេចមកហើយដែរ ដើម្បី ទប់ទល់នូវ ហេតុការណ៍សំខាន់ៗដែលនឹងកើតមានឡើងនៅពេលអនាគត់ ។ ប៉ុន្តែចំពោះយើង ខេម រិទ្ធ មើលមិនឃើញទាល់តែសោះថាក្រុមលោក ហ៊ុន សែន និង ឈ្មុះ ក្រុមលោក ជា ស៊ីម ដែលមានរដ្ឋាភិបាលយួនកម្មុយនិស្តក្រុងហាណូយ ជាកម្លាំងសំខាន់ជួយអន្តរាគមន៍នៅពីក្រោយ ។

**បើយើងមើលទៅតាមសភាពការណ៏ ដូចដែលបានរៀបរាប់ត្រួសៗ មកខាងលើនេះ យើង ពិតជាមើលឃើញយ៉ាងច្បាស់ថា ប្រទេសកម្ពុជាយើងពិតជាមានសង្គ្រាមរវាងខ្មែរ និង ខ្មែរ ម្តងទៀត ប៉ុន្តែយើងជឿ ជាក់ថា សង្គ្រាមនោះនឹងមិនប្រើរយះពេលយូរប៉ុន្មានទេ ឬ យើងអាចហៅតាមពុទ្ធទំនាយថា (សង្គ្រាមមួយចំអិនកំពឹស) ហ្នឹងហ្មែង ៕**

**ខាងក្រោមនេះយើងសូមធ្វើការព្រមានជាចំហដល់ក្រុមលោក ហ៊ុន សែន ដែលកំពុងចាញ់ប្រៀបសត្រូវ ៕**

ដូចអ្វីដែលយើងបានធ្វើការវិភាគ និង អធិប្បាយត្រួសៗ មកខាងលើនេះ យើងឃើញថា គ្រប់បញ្ហា និង វិបត្តិ ទាំងអស់ដែលកំពុងនឹងកើតមានឡើងនាពេលខាងមុខនេះហ្នឹង គឺបង្កឡើងដោយ ពពួកជនកម្មុយនិស្តក្នុងគណបក្សប្រជាជនកម្ពុជាដែលកំពុងព្យាយាមដណ្តើមអំណាចពីគ្នាឯង ដើម្បីតម្រូវចិត្តចៅហ្វាយនាយខ្លួន ដោយមានម្ខាងជាខ្ញុំកញ្ជះចិន និង ម្ខាងទៀតជាខ្ញុំកញ្ជះយួន គឺវានឹងដើរទៅតាមគន្លងចាស់របស់ក្រុម ប៉ុល ពត ( ដែលគួរអោយយើងអស់សំណើចណាស់ ) ។

នាពេលនេះយើង ខេម រិទ្ធ បានយល់យ៉ាងច្បាស់ថាក្រុមលោក ហ៊ុន សែន ឥឡូវនេះកំពុងតែរើបំរះ ខ្លួនចេញពី ( **នឹមដែក** ) របស់យួនកម្មុយនិស្តក្រុងហាណូយ ដោយមានសំអាងទៅលើចិនកម្មុយនិស្ត ក្រុងប៉េកាំងឈរនៅពីក្រោយខ្នង ។

ប៉ុន្តែសម្រាប់យើងវិញយើងមានជំនឿថាវាពិតជាមិនគ្រប់គ្រាន់ទេសម្រាប់ក្រុមលោកហ៊ុន សែន បើក្រុមនេះ មិនមានជនជាតិខ្មែរ មកចូលរួមអោយបានជា កម្លាំងអ្នកស្នេហាជាតិពិតប្រាកដមួយ ដើម្បី ធ្វើការ តស៊ូ ទប់ទល់ និង កម្លាំងបង្កប់របស់យួនដែលមានទាំងកម្លាំងកងទ័ព កម្លាំងប្រជាជនរាប់លាននាក់នៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ ។

អស់រយះពេល 30 ឆ្នាំ កន្លងមកហើយដែលលោក ហ៊ុន សែន ខ្លួនឯងបាន ធ្វើភ្លៀង ធ្វើផ្គរ នៅលើទឹកដីដែលជាអតីតមហានគរមួយនេះ មិនមែនព្រោះតែរដ្ឋាភិបាលយួនក្រុងហាណូយជាអ្នកជួយ ឧបត្ថម និង គាំទ្រ ជារៀងរហូតមកទេឬ ? ។ ហើយតាំងតែពីយួនគេលើកបន្តុប់អោយធ្វើជា នាយករដ្ឋមន្ត្រីអាយ៉ង រហូតមកដល់ សព្វថ្ងៃនេះ លោក ហ៊ុន សែន មិនដែល គិត ឬ ចាត់ទុកថា ជនជាតិខ្មែរជាមិត្តម្តងណាឡើយ ពីព្រោះខ្លួនបានយល់ និង បានដឹង យ៉ាងច្បាស់ថា ជនជាតិខ្មែរស្ទើតែទាំងអស់បានចាត់ទុកថាខ្លួន ជាសត្រូវ ជាជនកម្មុយនិស្តផ្តាច់ការ ជាជនឧក្រិដ្ឋ ជាជនក្បត់ជាតិ ជាជនលក់ជាតិ ។ល។ និង។ល។

ក្នុងរយះពេល 30 ឆ្នាំ **ក្នុងអំណាច ក្នុងអំនួត** ដែលថាខ្លួនជានាយករដ្ឋមន្ត្រីមានវ័យក្មេងជាង គេនៅក្នុងអំណាចយូរជាងគេ ប៉ុន្តែលោក ហ៊ុន សែន ខ្លួនឯងហ្នឹងគឺដឹងច្បាស់ជាងគេថា ក្នុង រយះពេល 30 ឆ្នាំ កន្លងមកនេះ ខ្លួនឥតដែលបានធ្វើអ្វី ដើម្បីជាប្រយោជន៍ជាតិខ្មែរ និង ប្រជាជនខ្មែរយើងឡើយ ដោយហេតុថាខ្លួនជាប់រវល់តែនឹង ផ្គាប់ចិត្តចៅហ្វាយ ក្រហាយនឹងអំណាច រកប្រយោជន៍សម្រាប់តែ ខ្លួន ក្រុមគ្រួសារខ្លួន វង្សត្រកូលខ្លួន និង បក្សពួកខ្លួន តែប៉ុណ្ណោះ ដោយមិនបានគិតថាខ្លួន ជានាយករដ្ឋមន្ត្រីនៃប្រទេសមួយ ដែលមាន ភារកិច្ច និង កត្តព្វកិច្ចត្រូវតែ កសាង រក្សា និង ការពារ អោយបាននូវ ផលប្រយោជន៍ជាតិ និង ប្រជាជនរបស់ខ្លួននោះឡើយ។

ដល់ពេលឥឡូវនេះទើប ភ្ញាក់ខ្លួន ភ្ញាក់គំនិត គិតថាអន្តរាយន៍កំពុងមកដល់ ប៉ុន្តែវាជិតហួស

ពេលទៅហើយលោក ហ៊ុន សែន អើយ បើយួនគេអន់ជាង ហ៊ុន សែន គេមិនមែនធ្វើជាចៅហ្វាយ ហ៊ុន សែន រហូតដល់ទៅ 33 ឆ្នាំរួចមកហើយនោះទេ ( **សូមកុំច្រឡំខុស** ) ។

ការដែលយើងនិយាយរបៀបនេះ មិនមែនបានន័យថាយើង មើលងាយ ឬ បន្តោកបន្ទាបខ្មែរដូចគ្នា រួចហើយទៅលើកសរសើរយួនដែលជាសត្រូវរបស់ខ្មែរនោះទេ ប៉ុន្តែយើងកំពុងតែនិយាយការពិត ព្រោះថាលោកជានាយករដ្ឋមន្ត្រីនៃប្រទេសខ្មែរ លោកត្រូវតែ បំរើ រក្សា និង ការពារ អោយបាននូវ ផលប្រយោជន៍ជាតិ និង មាតុភូមិខ្មែរ ជាពិសេសបំផុតនោះគឺ ( **ព្រលឹងជាតិខ្មែរ** ) ( **ពីព្រោះឥឡូវនេះគឺវាជិតហួសពេលទៅហើយ** ) ។

រឿងដែលសំខាន់ និង ជាក្តីព្រួយបារម្ភណ៍របស់ប្រជាជាតិខ្មែរយើងទាំងមូលនា ពេលអនាគត់ នោះគឺ ជោគវាសនា និង អនាគត់ របស់ជាតិមាតុភូមិកម្ពុជាយើងដែលខ្មែរយើងគ្រប់ៗគ្នា ត្រូវតែធ្វើការ ទាមទារ ធ្វើការកសាង ធ្វើការរក្សា និង ការពារ អោយបាននោះគឺ ៖

1- បញ្ឈប់ជាបន្ទាន់នៅការបោះបង្គោលព្រំដែន ខ្មែរ-យួន ។

2 - បញ្ឈប់ និង ទប់ស្កាត់ជាបន្ទាន់នូវ និគមន៍ជនជាតិយួនចូលមកខុសច្បាប់ក្នុងប្រទេសកម្ពុជា ។

3- ធ្វើការសើរើ និង ត្រួតពិនិត្យឡើងវិញនូវ បណ្តាជនជាតិយួនដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជានាបច្ចុប្បន្ន ។

4- បញ្ឈប់ជាបន្ទាន់នៅការចេញប័ណ្ណគ្រួសារ និង ប័ណ្ណបោះឆ្នោត ហើយធ្វើការរឹបអូសយកមកវិញនូវប័ណ្ណទាំងអស់ណាដែលបានផ្តល់អោយដោយមិនត្រឹមត្រូវ ។

5- ធ្វើការរំលាយ និង រំសាយ អោយអស់នូវ សមាគមន៍ និង សហាគមន៍ ជនជាតិយួនទាំងអស់ក្នុងប្រទេសកម្ពុជា ។

6- ប្រកាសទាមទារយកកោះខ្មែរក្នុងសមុទ្រមួយចំនួនដែលយួនកំពុងកាន់កាប់មកវិញ ។

7- ប្រកាសផ្តាច់ខ្លួនចេញអោយផុតពីក្រោមសំពាតនយោបាយរបស់សត្រូវយួនឈ្លានពាន ។

ទាំង 07 ប្រការខាងលើនេះគឺមានសារ:សំខាន់ណាស់សម្រាប់អាយុជីវិតជាតិ និង មាតុភូមិកម្ពុជាយើង ដូច្នេះនេះជាឱកាសសម្រាប់ក្រុមលោក ហ៊ុន សែន ហើយ បើក្រុមលោក ហ៊ុន សែន មិនយកឱកាសនេះមកដើម្បីបង្រួបបង្រួមជាតិ និង ផ្សះផ្សារជាតិអោយបានទៅជាកម្លាំងជាតិពិតប្រាកដមួយទេនោះ យើងមានជំនឿថាជោគវាសនា និង អនាគត់ របស់ក្រុមលោក ហ៊ុន សែន គឺមិនខុសពី ( ប៉ុល ពត )( សាដាម ហ៊ុសសេន ) និង ( មម៉ា ហ្គាដាហ្វី ) នោះឡើយ ។

**លោក ហ៊ុន សែន ក្នុងនាមលោកជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ហើយយើងជឿជាក់ ថានេះជា ឱកាសចុងក្រោយរបស់លោកហើយដែលអាចធ្វើអ្វីៗដើម្បីជាតិ និង ប្រជាជនរបស់ខ្លួន នៅមុនពេល ដែល លោកគ្មានឱកាសនឹងធ្វើ ពីព្រោះយើង ខេម រិទ្ធ មើលមិនឃើញឱកាសសម្រាប់លោក តទៅទៀតឡើយ ។**

ដូច្នេះចាប់តាំងពីថ្ងៃនេះតទៅយើងចង់ឃើញខ្មែរ និង ខ្មែរ ខ្មែរគ្រប់និន្នាការនយោបាយរួបរួមសាមគ្គីគ្នា អោយបានជាកម្លាំងជាតិពិតប្រាកដមួយ ដែលមានភាពស្មោះត្រង់នឹងគ្នា ជឿទុកចិត្តលើគ្នាទៅវិញទៅមក មិនបោកប្រាសគ្នា មិនក្បត់គ្នា ព្រោះតែបំរើប្រយោជន៍អោយពួកបរទេស ដូចពីអតីតកាលទៀតនោះ ហើយយើងមានជំនឿថាលោក ហ៊ុន សែន ពិតជាធ្វើបាន ក្នុងនាមខ្លួនជានាយករដ្ឋមន្ត្រី ។

**ស៊ូស្លាប់ខ្លួន មិនអោយស្លាប់ជាតិ មិនក្បត់ជាតិ ក្បត់ប្រជាជន**

**មិនលោភលន់នឹងអំណាច មិនខ្លបខ្លាច មិនចុះចាញ់ ។**

ធ្វើនៅថ្ងៃទី 19 ធ្នូ ឆ្នាំ 2012

ខេម រិទ្ធ